00334686

D158/5/4/10

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

| | | |
|---|---|---|
| **បណ្តឹងឧទ្ធរណ៍លេខ** | : | ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ១៩,២០,២១, & ២២) PTC 19 |
| **ថ្ងៃដាក់** | : | ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៩ |
| **ភាគីអ្នកដាក់** | : | ការិយាល័យសហព្រះរាជអាជ្ញា |
| **ភាសាដើម** | : | ភាសាអង់គ្លេស |
| **ប្រភេទឯកសារដែលស្នើឡើង** | : | សាធារណៈ |

---

**ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញានៅនឹងបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី ប្រឆាំងនឹងដីកាសម្រេចបដិសេធរបស់សហចៅក្រមស៊ើបអង្កេតនៅនឹងសំណើសុំឲ្យមានកិច្ចស៊ើបសួរ ជាក់លាក់នឹងការចោទប្រកាន់អំពីអំពើពុករលួយ**

---

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification): 01 / JUN / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: [signature]

**ដាក់ជូនដោយ:**

**ការិយាល័យសហព្រះរាជអាជ្ញា:**
លោកស្រី ជា លាង
លោក Robert PETIT
លោក យ៉េត ចរិយា
លោក William SMITH
លោក សេង ប៊ុនឃាង
លោក Vincent de WILDE d'ESTMAEL
លោក Anees AHMED

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de réception): 29 / 05 / 2009
ម៉ោង (Time/Heure): 12:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: UCH ARUN

**ចែកចាយជូន:**

**អង្គបុរេជំនុំជម្រះ:**
ចៅក្រម ប្រាក់ គឹមសាន (ប្រធាន)
ចៅក្រម Rowan DOWNING
ចៅក្រម ន៉ីយ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

**សហមេធាវីការពារក្តីជនត្រូវចោទ/ ភាគីម្ចាស់បណ្តឹងឧទ្ធរណ៍៖**
សុន អារុណ
Michiel PESTMAN
អាង ឧត្តម
Michael G. KARNAVAS
ផាត់ ពៅស៊ាង
Diana ELLIS
ស សុវាន
Jacques VERGES

00334687

# មាតិការឿង


**១. សេចក្តីផ្តើម** ...............................................................

១.១ ប្រវត្តិសាវតា ...............................................................

១.២ បណ្តឹងឧទ្ធរណ៍ទាំងអស់ពាក់ព័ន្ធនឹងរឿងដូចៗគ្នា ..............................

**២. សេចក្តីសង្ខេបនៃនត្ថិករណ៍** ...............................................

**៣. សារជាតិនៃចម្លើយតបនេះ** ...................................................

៣.១ ការចោទប្រកាន់ពីអំពើពុករលួយដែលគ្មានការបង្ហាញភស្តុតាង ...............

៣.២ ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ពុំត្រូវបានបដិសេធទេ .............

៣.៣ សារជាតិនៃបណ្តឹងឧទ្ធរណ៍អនុញ្ញាតឲ្យរបស់សហព្រះរាជអាជ្ញាធ្វើចម្លើយតបរួម...........................................................................

**៤. សេចក្តីសន្និដ្ឋានបឋម** ...................................................

៤.១ សវនាការផ្ទាល់មាត់ ...............................................................

**៥. ចម្លើយតប** ...............................................................

៥.១ សេចក្តីផ្តើម ...............................................................

៥.២ អំពើពុករលួយនៅ អ.វ.ត.ក...............................................

*៥.២.១ អំពើពុករលួយគឺជាការរំលោភបំពានលើអំណាច និងត្រូវតែដោះស្រាយ* ...............................................

*៥.២.២ អំពើពុករលួយដែលបានចោទប្រកាន់ពុំមែនជាអំពើពុករលួយរបស់តុលាការនោះទេ*...............................................

៥.៣ ច្បាប់ជាធរមាន ...............................................................

*៥.៣.១ គោលការណ៍មូលដ្ឋានសម្រាប់គ្រប់គ្រងតុលាការនេះ* ..............

*៥.៣.២ អំណាចលក្ខន្តិកៈរបស់សហចៅក្រមស៊ើបអង្កេត* .................

*៥.៣.២.១ ទូទៅ* ...............................................................

*៥.៣.២.២ អំណាចក្នុងការស៊ើបអង្កេត* ..............................

*៥.៣.២.៣ អំណាចក្នុងការដាក់ទណ្ឌកម្ម* ..............................

*៥.៣.២.៤ យន្តការសម្រាប់ការដឹតចិត្ត* ..............................

00334688




៥.៣.៣ អំណាចទាំងឡាយដែលត្រូវបានទទួលស្គាល់ថា"មានជាប់មកជាមួយ
ស្រាប់ពីធម្មជាតិ"ដោយតុលាការផ្សេងៗទៀតគឺជាលក្ខន្តិក:
នៅអ.វ.ត.ក ..........................................................

៥.៣.៤ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនត្រូវចោទ
ដែលតុលាការនេះជាអ្នកជំនុំជម្រះ.....................................

៥.៣.៤ ការវិនិច្ឆ័យភាពលម្អៀងបានហ៊ុំព័ទ្ធលើភាពលម្អៀងពិតប្រាកដនិង
ភាពលម្អៀងដែលត្រូវបានគេយល់ឃើញ ..........................

៥.៣.៥ បណ្តឹងសុំឲ្យមានការវិនិច្ឆ័យលើភាពលម្អៀងនៅក្នុង
យុត្តាធិការអន្តរជាតិនានា ..................................................

៥.៣.៦ ឯករាជ្យភាពនិងភាពអនាគតិរបស់មន្ត្រីតុលាការដែល
មិនមែនជាចៅក្រម ......................................................

៥.៣.៧ ការប្រព្រឹត្តដែលមិនពាក់ព័ន្ធទៅនឹងការធ្វើសេចក្តីសម្រេចរបស់
តុលាការគឺមិនប៉ះពាល់ដល់សិទ្ធិក្នុងការទទួលបាននូវការ
កាត់សេចក្តីដោយយុត្តិធម៌នោះទេ ....................................

៥.៤ ទទ្បីករណ៍ ..........................................................................

៥.៤.១ សំណើសុំនេះគឺមិនស្ថិតនៅក្នុងយុត្តាធិការតាមច្បាប់លក្ខន្តិក:
របស់សហចៅក្រមស៊ើបអង្កេតនោះទេ ...............................

៥.៤.២ នីតិវិធីនៃការប្តឹងជិតចិត្តតាមផ្លូវតុលាការមិនអាចយកមក
អនុវត្តបានទេ..........................................................................

៥.៤.៣ ការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលមិនមានការ
បង្ហាញភស្តុតាងទេ.....................................................

៥.៤.៤ សំណើសុំនេះមិនស្ថិតនៅក្នុងយុត្តាធិការដែលមាន
ជាប់មកជាមួយស្រាប់របស់តុលាការនោះទេ........................

៥.៤.៥ ការធ្វើសេចក្តីសម្រេចរបស់តុលាការមិនត្រូវបានប៉ះពាល់
ដោយអំពើពុករលួយផ្នែករដ្ឋបាលដែលបានចោទប្រកាន់នោះទេ......

៥.៤.៦ វិធានផ្ទៃក្នុងមិនអនុញ្ញាតឲ្យមានសំណើសុំពត៌មានដែលមិន
មានការចង្អុលបង្ហាស្តុតាងនោះទេ.....................................

00334689



*៥.៤.៧ តុលាការនេះមិនមែនជាវេទិកាសម្រាប់ធ្វើការស៊ើបអង្កេតលើអំពើពុករលួយក្រៅពីដំណើរការរឿងក្តីរបស់តុលាការនោះទេ............*

*៥.៤.៨ ឧបាស្រ័យពីផ្នែកខាងក្រៅមិនបានធ្វើឱ្យអស់លទ្ធភាពទេ ...........*

៥.៥ គួរតែជម្រុញលើកទឹកចិត្តឱ្យអាជ្ញាធរពាក់ព័ន្ធធ្វើការផ្សព្វផ្សាយរបាយការណ៍ OIOS នេះ.......................................................

**៦. សេចក្តីសន្និដ្ឋាន** ........................................................................

00334690



## ១. សេចក្តីផ្តើម

### ១.១ ប្រវត្តិសាវតា

១. សហព្រះរាជអាជ្ញាសូមដាក់ចម្លើយតបរួមនេះ ("ចម្លើយតប") ទៅនឹងបណ្តឹងឧទ្ធរណ៍ ("បណ្តឹងឧទ្ធរណ៍") របស់ជនត្រូវចោទ នួន ជា[1] អៀង សារី[2] អៀង ធីរិទ្ធ[3] និង ខៀវ សំផន[4] ("ភាគីប្តឹងឧទ្ធរណ៍") ដែលម្នាក់ៗ ចង់ឱ្យមានការកែប្រែដីការួមរបស់សហចៅក្រមស៊ើបអង្កេត (ដីកា)ស្តីពីសំណើសុំឱ្យមានកិច្ចស៊ើបសួរ ("សំណើ") ទាក់ទិននឹងការចោទប្រកាន់អំពីអំពើពុករលួយក្នុងផ្នែករដ្ឋបាលតុលាការនេះ[5]។ សំណើដែលដាក់ជូន

---

[1] *រឿងក្តី នួន ជា* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ២១), បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើលើកទី១១ ស្នើសុំបំពេញកិច្ចស៊ើបសួរ, ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០០៩, ឯកសារលេខ D158/5/1/1 [*បន្ទាប់ពីនេះ* បណ្តឹងឧទ្ធរណ៍របស់ នួន ជា]។

[2] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ២០), បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំបំពេញ កិច្ចស៊ើបសួរ អំពីការចោទប្រកាន់ជាហូរហែរអំពី អំពើពុករលួយ និងសំណើសុំចាត់ការសវនាការដេញដោលផ្ទាល់មាត់ឱ្យឆាប់រហ័ស, ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០០៩, ឯកសារ លេខ D158/5/3/1 [*បន្ទាប់ពីនេះ* បណ្តឹងឧទ្ធរណ៍របស់ អៀង សារី]។

[3] *រឿងក្តី អៀង ធីរិទ្ធ* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ១៩), បណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹង "ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ" ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៩ របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត, ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០០៩, ឯកសារលេខ D158/5/4/1 [*បន្ទាប់ពីនេះ* បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ]។

[4] *រឿងក្តី ខៀវ សំផន* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ២២), *បណ្តឹងឧទ្ធរណ៍របស់ក្រុមការពារក្តីលោក ខៀវ សំផន ប្រឆាំងនឹង "ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេត" ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៩,* ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០០៩, ឯកសារលេខ D158/5/2/1 [*បន្ទាប់ពីនេះ* បណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន]។

[5] *រឿងក្តី នួន ជា* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី១១, ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៩, ឯកសារលេខ 158/5 [*បន្ទាប់ពីនេះ* ដីកា]។

00334691



ដោយជនត្រូវចោទ នួន ជា សុំឱ្យសហចៅក្រមស៊ើបអង្កេតដើម្បីឱ្យផ្តល់ និងចេញផ្សាយ ព័ត៌មានមួយចំនួនពាក់ព័ន្ធនឹងការចោទប្រកាន់អំពីអំពើពុករលួយ រួមទាំងរបាយការណ៍ ស៊ើបអង្កេតរបស់ការិយាល័យសេវាកម្មទទួលបន្ទុកកិច្ចការផ្ទៃក្នុងរបស់អង្គការសហប្រជាជាតិ ("របាយការណ៍ OIOS") ដែលនិយាយពាក់ព័ន្ធទៅដល់ការចោទប្រកាន់ទាំងនោះ[6]។ សំណើនោះក៏"ស្នើសុំឱ្យ" សហចៅក្រមស៊ើបអង្កេត ធ្វើការស្នើសុំឱ្យមានកិច្ចស៊ើបអង្កេត ទៅលើការចោទប្រកាន់ទាំងនោះ ដែលមាននៅក្នុងផ្នែករដ្ឋបាល[7]។ ជនត្រូវចោទ អៀង សារី អៀង ធីរិទ្ធ និង ខៀវ សំផន បានដាក់ពាក្យសុំនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ដើម្បី "ចូលរួម" "យល់ព្រម" ឬ "គាំទ្រ" សំណើនោះ។

២. ដីកានោះបានបដិសេធសំណើនោះដោយហេតុថា (១) សហចៅក្រមស៊ើបអង្កេត"ខ្វះយុត្តាធិការក្នុងការអនុវត្តន៍កិច្ចស៊ើបសួរ" និង(២) គ្មានមូលដ្ឋានសម្រាប់ស្នើសុំឱ្យធ្វើការស៊ើបអង្កេតរដ្ឋបាល"[8]។

### ១.២ បណ្តឹងឧទ្ធរណ៍ទាំងអស់ពាក់ព័ន្ធនឹងរឿងដូចៗគ្នា

៣. បើទោះបីជាការចេញដីកានោះឈរលើមូលដ្ឋាន នៃសារណាសំខាន់របស់តែមួយភាគីក្តី (នួន ជា) ក៏ដីកានោះដូចដែលបានបញ្ជាក់រួចហើយ គឺថាត្រូវបានជនត្រូវចោទទាំងបួននាក់ ប្តឹងឧទ្ធរណ៍ប្រឆាំងជំទាស់។ ជនទាំងបួននាក់នោះគឺជាភាគី ក្នុងសំណុំរឿងលេខ ០០២។ ហេតុនេះ បណ្តឹងឧទ្ធរណ៍របស់ពួកគេបានលើកឡើងអំពីអង្គហេតុ និងបញ្ហាផ្លូវច្បាប់ដូចគ្នា ឬស្រដៀងគ្នា។

---

[6] *រឿងក្តី នួន ជា* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, សំណើលើកទី១១ ស្នើសុំបើកកិច្ចស៊ើបសួរ, ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩, ឯកសារលេខ D158 [*បន្ទាប់ពីនេះ* សំណើ]។

[7] សំណើ, កថាខណ្ឌទី២២។

[8] ដីកា, កថាខណ្ឌទី១៣។

៤. បណ្តឹងឧទ្ធរណ៍របស់ នួន ជា បានលើកឡើងថា ការដែលសហចៅក្រមស៊ើបទាត់ចោលសំណើនោះគឺ "ពុំត្រឹមត្រូវតាមផ្លូវច្បាប់ គោលនយោបាយសាធារណៈ និងសុភវិនិច្ឆ័យ"[9]។ បណ្តឹងឧទ្ធរណ៍នោះបានលើកអំណះអំណាងថា យុត្តាធិការរបស់សហចៅក្រមស៊ើបអង្កេត "ស្ទើរតែពុំមានកម្រិតដូចដែលបានលើកឡើងក្នុងដីកា របស់សហចៅក្រមស៊ើបអង្កេតនោះឡើយ" ហើយយុត្តាធិការនោះមានអំណាចពីធម្មជាតិ ដែលត្រូវបំពេញតាមការស្នើសុំ[10]។ បណ្តឹងឧទ្ធរណ៍នោះលើកឡើងថាសំណើសុំនោះគឺត្រូវបានជម្រុញធ្វើឡើងដោយមានអង្គហេតុគ្រប់គ្រាន់ បើសិនជាយកផលប្រយោជន៍គេស្នើសុំមកពិចារណា[11] ហើយវានឹង "គ្មានប្រយោជន៍" ដែលត្រូវរង់ចាំដំណោះស្រាយអំពីបញ្ហា[អំពើពុករលួយ]ពីរដ្ឋាភិបាលកម្ពុជា និង/ឬ អង្គការសហប្រជាជាតិ[12]។

៥. ដូចគ្នានេះ បណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ អៀង សារី បានលើកឡើងថា កិច្ចស៊ើបអង្កេតដែលគេស្នើសុំឲ្យមាននោះ គឺស្ថិតនៅក្នុងយុត្តាធិការផ្លូវច្បាប់[13] និងយុត្តាធិការពីធម្មជាតិ[14]របស់សហចៅក្រមស៊ើបអង្កេត។ យុត្តាធិការពីធម្មជាតិពាក់ព័ន្ធទៅនឹងភារកិច្ចនៃតុលាការក្នុងការធានាយុត្តិធម៌ និងភាពមិនលម្អៀងក្នុងកិច្ចដំណើរការក្តីខាងតុលាការរបស់ខ្លួន[15]។ បន្ទាប់ពីបណ្តឹងឧទ្ធរណ៍របស់ នួន ជា បណ្តឹងឧទ្ធរណ៍នេះលើកទឡ្ហីករណ៍ថាធាតុផ្សំនៃសំណើនេះត្រូវបាន "គេកត់សម្គាល់ឃើញច្បាស់ [និង] ពាក់ព័ន្ធទៅនឹងសិទ្ធិពុំគ្រប់គ្រាន់ ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌"[16] ហើយថាសហចៅក្រម

---

[9] បណ្តឹងឧទ្ធរណ៍របស់ នួន ជា, កថាខណ្ឌទី៣៥។

[10] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌទី២២-២៥។

[11] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌទី២៦-៣០។

[12] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌទី៣១-៣៤។

[13] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌទី១៨-២១។

[14] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌទី២២-៣៤។

[15] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌទី២២។

[16] ដូចជើងទំព័រខាងលើ, ទំព័រទី១។

ស៊ើបអង្កេតបានអនុវត្តន៍ "វិធីសាស្ត្រដាក់កំហិតហួសហេតុ ក្នុងការកំណត់ព្រំដែននៃយុត្តាធិការលក្ខន្តិកៈរបស់ពួកគេ"[17]។

៦. បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ បានលើកយកទឡ្ហីករណ៍ទាំងឡាយក្នុងបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ នួន ជា មកនិយាយតែប៉ុណ្ណោះ[18]។

៧. បណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ដែលស្រដៀងទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា បានលើកទឡ្ហីករណ៍ថា សហចៅក្រមស៊ើបអង្កេតមានយុត្តាធិការក្នុងការទទួលសំណើសុំនេះ[19]។ បណ្តឹងឧទ្ធរណ៍នោះបានអះអាងថា ការដែលសហចៅក្រមស៊ើបអង្កេតខកខានពុំបានអនុវត្តន៍សកម្មភាពតាមការស្នើសុំ មានន័យស្មើនឹងការរំលោភនីតិរដ្ឋ និងធ្វើឲ្យបរាជ័យក្នុងការធ្វើឲ្យមានដំណើរការតុលាការដែលប្រកបដោយសមធម៌ និងយុត្តិធម៌[20]។

## ២. សេចក្តីសង្ខេបទឡ្ហីករណ៍

៨. ការចោទប្រកាន់អំពីអំពើពុករលួយនៅ អ.វ.ត.ក ជាពិសេស ការចោទប្រកាន់ថាមន្ត្រីផ្នែករដ្ឋបាលភាគីកម្ពុជា បានចំណាយប្រាក់ដើម្បីជាថ្នូរនឹងតួនាទីនៅតុលាការនេះ[21] បានធ្វើឲ្យខូចកេរ្តិ៍ឈ្មោះតុលាការនេះ និងបានលើកឡើងអំពីការមន្ទិលសង្ស័យនានាអំពីទំនុកចិត្ត និងកេរ្តិ៍តំណែលរបស់វា។ អំពើពុករលួយក្នុងរូបភាពណាក៏ដោយ គឺយើងពុំអាចទទួលយកបានទេ ហើយនឹងត្រូវតែស៊ើបអង្កេត និងដោះស្រាយដោយសមត្ថកិច្ចឲ្យបានត្រឹមត្រូវ។ សហព្រះរាជអាជ្ញា សូមបញ្ជាក់អំពីបំណងរបស់ខ្លួន ក្នុងការចង់ឃើញការដោះស្រាយ

---

[17] *ដូចដើងទំព័រខាងលើ*, កថាខណ្ឌទី១៣។

[18] "ម្ចាស់បណ្តឹងឧទ្ធរណ៍ ទទួលយកសេចក្តីសំអាងដែលមានក្នុង "បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើលើកទី១១ ស្នើសុំបំពេញកិច្ចស៊ើបសួរ"៖ បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, កថាខណ្ឌទី៦។

[19] បណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន, កថាខណ្ឌទី[៧]។

[20] *ដូចដើងទំព័រខាងលើ*, កថាខណ្ឌទី [១៦]។

[21] សូមមើល សំណើ, កថាខណ្ឌទី៤-១១; បណ្តឹងឧទ្ធរណ៍របស់ នួន ជា, កថាខណ្ឌទី២-៦; បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌទី២។

ឱ្យបានឆាប់រហ័ស និងត្រឹមត្រូវចំពោះបញ្ហាដែលញាំញីតុលាការនេះរយៈពេលចំនួនជាង ២ ឆ្នាំកន្លងមកនេះ។

៩. បើទោះបីជាដូច្នេះក្តី ក្នុងកាលៈទេសៈបណ្តឹងឧទ្ធរណ៍ទាំងនេះ កិច្ចស៊ើបសួរដែលគេបានស្នើសុំ វាស្ថិតនៅក្រៅវិសាលភាពនៃអំណាចស៊ើបសួរ របស់សហចៅក្រមស៊ើបអង្កេត។ ហើយក៏គ្មានអំណាចពីធម្មជាតិណាមួយរបស់តុលាការនេះ ជម្រុញឱ្យពួកគេទទួលយកសំណើសុំឱ្យមានកិច្ចស៊ើបអង្កេតនោះឡើយ។ អំណាចរបស់សហចៅក្រមស៊ើបអង្កេតក្នុងការអនុវត្តកិច្ចស៊ើបសួរ គឺកម្រិតត្រឹមតែដែននៃយុត្តាធិការសំខាន់របស់តុលាការ ដើម្បីកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរយៈកាលរបបកម្ពុជាប្រជាធិបតេយ្យ ចន្លោះពីឆ្នាំ១៩៧៥ ដល់១៩៧៩ តែប៉ុណ្ណោះ[22] និង "អង្គហេតុដែលលើកឡើងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបន្ថែម"[23]។

១០. លើសពីនេះ នៅក្នុងបណ្តឹងឧទ្ធរណ៍ទាំងនោះ គ្មានអ្វីដែលបង្កើតឱ្យមានទំនាក់ទំនងរវាងអំពើពុករលួយដែលបានត្រូវបានចោទប្រកាន់ និងការចេញសេចក្តីសម្រេច របស់តុលាការនេះឡើយ។ ហើយបណ្តឹងឧទ្ធរណ៍ទាំងនោះក៏ពុំបានចោទថាមានការរំលោភទៅលើសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ របស់ភាគីម្ចាស់បណ្តឹងឧទ្ធរណ៍នោះទេ ប្រសិនបើវាជាការពិត សហចៅក្រមស៊ើបអង្កេតនឹងមានអំណាចក្នុងការ (១) ដាក់ទណ្ឌកម្មដល់ការជ្រៀតជ្រៀកណាមួយក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ (វិធានផ្ទៃក្នុង ៣៥ ("វិធាន") (២) សុំមោឃៈភាពនូវកិច្ចដំណើរការនីតិវិធី ចំពោះ "ការខ្វះចន្លោះខាងនីតិវិធី"

---

[22] ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សម្រាប់កាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ, ត្រូវបានធ្វើវិសោធនកម្មស្របតាមកិច្ចព្រមព្រៀងចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤, នស/រកម/១០០៤/០០៦, មាត្រា២[*បន្ទាប់ពីនេះ* "ច្បាប់ អ.វ.ត.ក"]។

[23] វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៣), ដូចដែលបានពិនិត្យឡើងវិញនៅថ្ងៃទី៦ ខែមីនា ឆ្នាំ២០០៩, វិធាន៥៥(២) [*បន្ទាប់ពីនេះ* វិធាន]។

(វិធាន៧៥) (៣) ធ្វើបណ្ដឹងជិតចិត្តទៅក្រុមមួយរូប ឬពីររូបក្នុងចំណោមក្រុមខ្លួនចំពោះភាពលម្អៀង (វិធាន ៣៤)។

១១. ការចោទប្រកាន់ថាមន្ត្រីផ្នែករដ្ឋបាលភាគីកម្ពុជាមួយចំនួននៃតុលាការនេះ ចំណាយលុយកាក់ដើម្បីទទួលបាន ឬរក្សាតួនាទីរបស់ពួកគេ ដែលជាការពុំអាចទទួលយកបានទោះបីនៅក្នុងស្ថាប័នណាក៏ដោយ ជាពិសេសក្នុងស្ថាប័នតុលាការ។ ការចោទប្រកាន់នោះគឺស្ថិតនៅ (១) ក្រោមសមត្ថកិច្ចដាក់វិន័យរបស់រដ្ឋាភិបាលកម្ពុជា (វិធាន ៦(៥)) ឬ (២) ក្រោមយុត្តាធិការព្រហ្មទណ្ឌសាមញ្ញ នៃសាលាដំបូងរាជធានីភ្នំពេញ។ នៅពេលថ្មីៗកន្លងមកនេះ ខណៈពេលរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ បានចូលរួមប្រជុំដើម្បីដោះស្រាយបញ្ហានេះយ៉ាងសកម្ម និងដោយទៀតទាត់ដើម្បីបង្កើតនូវយន្តការត្រួតពិនិត្យមួយដ៏មានអត្ថន័យនោះ មេធាវីបរទេសរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ ដ៏សំខាន់ឈ្មោះ នួន ជា បានផ្ដើមឲ្យមានកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ចំពោះមុខសាលាដំបូងរាជធានីភ្នំពេញ។ កិច្ចដំណើរការនីតិវិធីទាំងពីរនេះ កំពុងតែដំណើរការ។

១២. ដោយសារហេតុផលទាំងនេះ សហព្រះរាជអាជ្ញាសូមអះអាងថា បណ្ដឹងឧទ្ធរណ៍គួរត្រូវបានបដិសេធចោល។

## ៣. សារជាតិនៃចម្លើយតបនេះ

### ៣.១ ការចោទប្រកាន់ពីអំពើពុករលួយដែលគ្មានភស្តុតាង

១៣. សហព្រះរាជអាជ្ញាកត់សម្គាល់ឃើញថា អំឡុងរយៈពេលជាងពីរឆ្នាំ មានការចោទប្រកាន់អំពីការបង់"លុយសូកប៉ាន់" របស់មន្ត្រីបុគ្គលិកជាតិ នៃអ.វ.ត.ក។ ទង្វើនោះ អាច ឬមិនអាច ឬកើតមានឡើង។ ទោះជាយ៉ាងដូច្នេះក្ដី សហព្រះរាជអាជ្ញា ពុំបានប្រកាន់ជំហរណាមួយ ទៅលើការសន្និដ្ឋានអង្គហេតុរបស់ភាគីម្ចាស់បណ្ដឹងឧទ្ធរណ៍នេះទេ លើកលែងតែដល់វិសាលភាពដែលសហព្រះរាជអាជ្ញាថ្លែងបញ្ជាក់ដោយផ្ទាល់នៅក្នុងចម្លើយតបនេះ។

### ៣.២ ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ពុំត្រូវបានបដិសេធទេ

១៤. ដូចបានបញ្ជាក់ បណ្តឹងឧទ្ធរណ៍ត្រូវបានដាក់ដោយឡែកពីគ្នា ដោយជនត្រូវចោទ នួន ជា អៀង សារី អៀង ធីរិទ្ធ និង ខៀវ សំផន ខណៈពេលដីកាដែលត្រូវជំទាស់នោះ ធ្វើឡើងដើម្បីបដិសេធសំណើសុំដ៏សំខាន់ដែលស្នើឡើងដោយភាគី នួន ជា តែមួយប៉ុណ្ណោះ។ បើទោះបីជាយ៉ាងដូច្នេះក្តី ក្នុងផលប្រយោជន៍នៃយុត្តិធម៌ និងជាដំណោះស្រាយឆាប់រហ័សទៅលើបណ្តឹងឧទ្ធរណ៍ សហព្រះរាជអាជ្ញាពុំប្រកាន់ជំហរណាមួយ ទៅលើបញ្ហានៃសិទ្ធិប្តឹងរបស់ អៀង សារី, អៀង ធីរិទ្ធ និង ខៀវ សំផន ក្នុងការប្តឹងឧទ្ធរណ៍ ឬការទទួលយកបណ្តឹងឧទ្ធរណ៍នោះទេ។

### ៣.៣ សារជាតិនៃបណ្តឹងឧទ្ធរណ៍ចាំបាច់នាំឲ្យមាន ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា

១៥. ដូចបានបញ្ជាក់ និងលើកឡើងពីខាងដើមដោយសហព្រះរាជអាជ្ញា ក្នុងពាក្យស្នើសុំបន្ថែមទំព័រ និងពេលវេលាកំណត់ ក្នុងការដាក់ចម្លើយតបរួម ទៅនឹងបណ្តឹងឧទ្ធរណ៍ទាំងនោះ បណ្តឹងឧទ្ធរណ៍ទាំងនោះត្រូវបានធ្វើឡើងសំដៅប្រឆាំងនឹងដីការួមរបស់សហចៅក្រមស៊ើបអង្កេត[24]។ បណ្តឹងឧទ្ធរណ៍ក៏លើកឡើងអំពីអង្គហេតុ និងបញ្ហាផ្លូវច្បាប់ផងដែរ[25]។ ដោយផ្អែកលើការពិចារណានេះ និងក្នុងផលប្រយោជន៍សេដ្ឋកិច្ចតុលាការ វាជាការមួយសមរម្យដែលបណ្តឹងឧទ្ធរណ៍ទាំងនេះ ត្រូវបានពិនិត្យ និងសម្រេចរួមដោយអង្គបុរេជំនុំជម្រះ[26]។

---

[24] *រឿងក្តី នួន ជា និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ១៩, ២០, ២១, & ២២), ពាក្យសុំរបស់សហព្រះរាជអាជ្ញា ស្តីពីការបន្ថែមចំនួនទំព័រ និងពន្យារពេលវេលាកំណត់ ដើម្បីដាក់ចម្លើយតបរបស់ខ្លួន ទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចអំពីអំពើពុករលួយ, ចុះថ្ងៃទី៦ ខែឧសភា ឆ្នាំ២០០៩, ឯកសារលេខ D158/5/4/2, កថាខណ្ឌទី២

[25] *ដូចជើងទំព័រខាងលើ។*

[26] *ដូចជើងទំព័រខាងលើ។*

00334697



ដូច្នោះ សហព្រះរាជអាជ្ញាសូមដាក់ចម្លើយតបនេះ ជាចម្លើយតបរួមទៅនឹងបណ្តឹងឧទ្ធរណ៍ ដើម្បីជួយអង្គបុរេជំនុំជម្រះ ក្នុងការសម្រេចបញ្ហាដែលបានលើកឡើង។

## ៤. ការអង្កេតបឋម

### ៤.១ សវនាការផ្ទាល់មាត់

១៦. ម្ចាស់បណ្តឹងឧទ្ធរណ៍នីមួយៗ ស្នើសុំឱ្យមានសវនាការផ្ទាល់មាត់ជាសាធារណៈមួយទៅលើបណ្តឹងឧទ្ធរណ៍ទាំងនោះ[27]។ សហព្រះរាជអាជ្ញាសូមមិនជំទាស់ទៅនឹងសវនាការផ្ទាល់មាត់នោះឡើយ។

១៧. បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ក៏បានស្នើសុំដែរថា ប្រសិនបើសវនាការផ្ទាល់មាត់ត្រូវបានអនុញ្ញាត ភាគីនីមួយៗគួរត្រូវបានអនុញ្ញាតពេលធ្វើការសន្និដ្ឋានសម្រាប់រយៈពេលប្រហែលមួយម៉ោងកន្លះ[28]។ ទាក់ទិននឹងម្ចាស់បណ្តឹងឧទ្ធរណ៍ អៀង ធីរិទ្ធ រយៈពេលនេះនឹងមិនសូវចាំបាច់ ដោយហេតុថាបណ្តឹងឧទ្ធរណ៍របស់គាត់គ្រាន់តែយកទឡ្ហីករណ៍ដែលបានលើកឡើងក្នុងបណ្តឹងឧទ្ធរណ៍របស់ នួន ជា មកនិយាយតែប៉ុណ្ណោះ[29]។ តាមរយៈការផ្តល់ការគាំទ្រក្នុងបណ្តឹងឧទ្ធរណ៍របស់ នួន ជា ទាំងស្រុង ជនត្រូវចោទ អៀង ធីរិទ្ធ កំពុងប្រកាន់ជំហរថាផលប្រយោជន៍របស់គាត់ នឹងត្រូវបានតំណាងយ៉ាងគ្រប់គ្រាន់ដោយទឡ្ហីករណ៍របស់ នួន ជា។ សិទ្ធិធ្វើការសន្និដ្ឋាន មិនមែនចាំបាច់ទាល់តែភាគីម្ចាស់បណ្តឹងឧទ្ធរណ៍ មានសិទ្ធិទទួលបានសវនាការផ្ទាល់មាត់ឡើយ។ វាអាចរួមបញ្ចូលនូវការកំណត់ជាសាធារណៈ និងមានសម្អាងហេតុ ទៅលើសារណាតបជាលាយល័ក្ខណអក្សរតែ

---

[27] បណ្តឹងឧទ្ធរណ៍របស់ នួន ជា, កថាខណ្ឌទី៣៥; បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌទី៩-១២; បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, កថាខណ្ឌទី៧; បណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន, កថាខណ្ឌទី៣៤។

[28] *ដូចជើងទំព័រខាងលើ,* កថាខណ្ឌទី១១។

[29] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, កថាខណ្ឌទី៦។

មួយ[30]។ នេះគឺជាការគ្រប់គ្រាន់សម្រាប់លក្ខខណ្ឌតម្រូវនៃភាពយុត្តិធម៌សម្រាប់កិច្ចដំណើរការនីតិវិធី[31] ។

## ៥. ចម្លើយតប

### ៥.១ សេចក្តីផ្តើម

១៨. បញ្ហាសំខាន់ដែលបានលើកឡើងក្នុងបណ្តឹងឧទ្ធរណ៍ទាំងនោះ គឺត្រង់បញ្ហាថាតើសហចៅក្រមស៊ើបអង្កេត មានអំណាចតាមច្បាប់ ដើម្បីទទួលយកសំណើនោះដែរឬយ៉ាងណា។ ដើម្បីឆ្លើយទៅនឹងសំណួរនេះ សហព្រះរាជអាជ្ញាសូមបញ្ជាក់ (១) យុត្តាធិការរបស់សហចៅក្រមស៊ើបអង្កេតតាមលក្ខខន្តិកៈ ឬតាមធម្មជាតិ ដែលត្រូវទទួលយកសំណើនោះ និង (២)ចរិកលក្ខណៈនៃភារកិច្ចរបស់តុលាការនេះក្នុងការការពារសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៃជនត្រូវចោទ និងដើម្បីធានាអំពីសុច្ចរិតភាពនៃកិច្ចដំណើរការនីតិវិធី និងដំណើរការរបស់ខ្លួន។

### ៥.២ អំពើពុករលួយដែលត្រូវបានចោទប្រកាន់ នៅ អ.វ.ត.ក

#### *៥.២.១ អំពើពុករលួយគឺជាការប្រើអំណាចបំពារបំពាន និងត្រូវតែដោះស្រាយ*

១៩. អំពើពុករលួយដែលត្រូវគេឲ្យនិយមន័យថា ជាការបំពារបំពាន ឬការប្រើប្រាស់មិនត្រឹមត្រូវនូវអំណាចដើម្បីផលប្រយោជន៍ឯកជន[32] គឺជាការដាក់បណ្តាសាដល់យុត្តិធម៌។

---

[30] *រឿងក្តី* *Jussila* *តទល់* *Finland,* សេចក្តីសម្រេចចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៦, ពាក្យបណ្តឹងលេខ 73053/01, Grand Chamber of the European Court of Human Rights, កថាខណ្ឌទី៤១។

[31] *Vilho Eskelimen និងគូគន ទល់នឹងប្រទេស ហ្វាំងឡង់,* សាលក្រម ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៧, ពាក្យសុំលេខ: 63235/00, អង្គជំនុំជម្រះខ្នាតធំនៃតុលាការសិទ្ធិមនុស្សអឺរ៉ុប, កថាខ័ណ្ឌទី៧៤ ។

បើទោះបីជាសិទ្ធិមនុស្សជាតិ និងអន្តរជាតិ ធានាថាចៅក្រមត្រូវឯករាជ្យ និងមិនលម្អៀង យ៉ាងណាក៏ដោយ ក៏អំពើពុករលួយបានជ្រៀតចូលក្នុងប្រព័ន្ធតុលាការ ក្នុងបណ្តាប្រទេសនានាទូទាំងពិភពលោក[33]។ នៅទីណាមានអំពើពុករលួយក្នុងប្រព័ន្ធតុលាការ ទីនោះមានការខូចខាតដែលអាចរីករាលដាល និងពិបាកបញ្ចៀសជាខ្លាំង។ ការប្រើអំណាចបំពារបំពានដូច្នេះ អាចនាំមកនូវឥទ្ធិពលមិនល្អ ទៅលើឯករាជ្យភាព និងភាពមិនលម្អៀងនៃដំណើរការតុលាការ និងអាចធ្វើឲ្យខូចដល់ដំណើរការយុត្តិធម៌[34]។

២០. អំពើពុករលួយត្រូវតែដោះស្រាយ។ អ.វ.ត.ក ពុំគ្រាន់តែធ្វើត្រឹមតែប្រតិបត្តិការប៉ុណ្ណោះទេ ប៉ុន្តែត្រូវឲ្យគេឃើញថាខ្លួនធ្វើប្រតិបត្តិការឲ្យបានក្នុងបទដ្ឋានខ្ពស់បំផុតនៃតម្លាភាព និងយុត្តិធម៌ ដោយគិតអំពីចរិកលក្ខណៈនៃកិច្ចដំណើរការនីតិវិធី និងភាពធ្ងន់ធ្ងរនៃបទចោទប្រឆាំងនឹងជនត្រូវចោទ នៅចំពោះមុខ អ.វ.ត.ក[35]។ ជាពិសេសតុលាការនេះត្រូវបង្ហាញឲ្យឃើញនូវការធានាដល់មូលដ្ឋានគ្រឹះរបស់តុលាការលើឯករាជ្យភាព និងភាពមិនលម្អៀង និងត្រូវរៀបចំសវនាការជាសាធារណៈ និងប្រកបដោយយុត្តិធម៌ ស្របតាមទស្សនាទាននៃយុត្តិធម៌ធម្មជាតិ ឬនីតិវិធីត្រឹមត្រូវ នៅក្រោមប្រព័ន្ធច្បាប់ក្នុងស្រុក និងអន្តរជាតិ[36]។ តុលាការចម្រុះ ឬកូនកាត់ ដូច អ.វ.ត.ក នេះ ទទួលបន្ទុកបន្ថែម ធ្វើជាតុលាការគំរូដែល

---

[32] Diabba Rodriguez, ed "សេចក្តីសង្ខេបរួម: បញ្ហាតុលាការសំខាន់ៗ" នៅក្នុងរបាយការណ៍ស្តីពីអំពើពុករលួយពិភពលោក: អំពើពុករលួយក្នុងប្រព័ន្ធយុត្តិធម៌ (អង្គការតម្លាភាពអន្តរជាតិ, ឆ្នាំ២០០៧ p. xxi [*បន្ទាប់ពីនេះតទៅហៅថា* របាយការណ៍អំពើពុករលួយពិភពលោក]។

[33] សូមមើល Justice Michael Kirby, 'Tackling Judicial Corruption -- Globally', សន្ទរកថានៅ St James Ethics Center, ទីក្រុង Sydney, អាចមើលបាននៅគេហទំព័រ http://www.hcourt.gov.au/speeches/ kirbyj/kirbyj_stjames.htm

[34] របាយការណ៍អំពើពុករលួយពិភពលោក, ទំព័រទី xvi។

[35] *រឿងក្តីរដ្ឋអាជ្ញា តទល់ Jean-Paul Akayesu,* សំណុំរឿងលេខ ICTR-96-4-T, កថាខណ្ឌទី២៩។ តុលាការ ICTY បានថ្លែងថា ភាពធ្ងន់ធ្ងរនៃការចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ មានន័យថា ICTY មានកាតព្វកិច្ចស្របជាមួយនឹងសាលាដំបូង និងតុលាការជាតិ ដើម្បីផ្តល់ឲ្យជនជាប់ចោទនូវការកាត់សេចក្តីដោយយុត្តិធម៌ដោយគោរពពេញលេញនូវសិទ្ធិរបស់គាត់ឬនាង។

[36] "កំណែទម្រង់ ILOAT"។ យោបល់ដែលរៀបរាងដោយ Geoffrey Robertson Q.C., Doughty Street Chambers, London, សម្រាប់ការប្រជុំព័ត៌មានស្តីពីកំណែទម្រង់តុលាការរដ្ឋបាល ILO និងបញ្ហាជាប់ទាក់ទង។ អាចមើលបាននៅលើគេហទំព័រ http://www.ilo.org/public/english/staffun/info/iloat/robertson.htm

ត្រូវតែអនុវត្តន៍ល្អជាងគេ សម្រាប់តុលាការក្នុងស្រុកយកទៅអនុវត្តតាម[37]។ ប្រសិនបើ អ.វ.ត.ក ពុំមានឯករាជ្យ និងលម្អៀង នោះ អ.វ.ត.ក មិនអាចរកយុត្តិធម៌តាមបទដ្ឋានសិទ្ធិមនុស្សជាតិ និងអន្តរជាតិបានឡើយ[38]។ អ្វីដែលគេយល់ថាជាឯករាជ្យភាព និងភាពមិនលម្អៀងនៃតុលាការ និងសាលាក្តីអន្តរជាតិ ជាបុរេលក្ខខណ្ឌចាំបាច់សម្រាប់ភាពស្របច្បាប់នៅក្នុងកែវភ្នែករបស់ភាគីទាំងឡាយ គូក្តី និងក៏ដូចជាសហគមន៍អន្តរជាតិ[39]។ សញ្ញាណនៃឯករាជ្យភាព និងភាពមិនលម្អៀង មានសារៈសំខាន់ចាំបាច់ដល់កេរ្តិ៍ឈ្មោះរយៈពេលវែង និងជំនឿទុកចិត្តទៅលើសាលក្រមស្ថាពរអន្តរជាតិ និងអន្តរជាតូបនីយកម្ម[40]។

### *៥.២.២ អំពើពុករលួយដែលបានចោទប្រកាន់ពុំមែនជាអំពើពុករលួយខាងតុលាការនោះទេ*

២១. ប្រវត្តិអង្គហេតុនៃការចោទប្រកាន់អំពីអំពើពុករលួយបានកំណត់ក្នុងសំណើនោះ[41] ហើយសហព្រះរាជអាជ្ញាពិចារណាឃើញថា ពួកគេពុំត្រូវការបញ្ជាក់អំពីភាពត្រឹមត្រូវទៅនឹងការពិត ដើម្បីកំណត់នៅក្នុងបណ្តឹងឧទ្ធរណ៍ទាំងនោះឡើយ។ ហេតុនេះសហព្រះរាជអាជ្ញាពុំធ្វើដូច្នេះឡើយ។

---

[37] Yuval Shany & Sigal Horovitz, ឯករាជ្យរបស់តុលាការ នៅក្នុងតុលាការ The Hague និងតុលាការ Freetown, *សារព័ត៌មាន Leiden នៃច្បាប់អន្តរជាតិ*, ២១ (២០០៨), ទំព័រទី១២០ [*បន្ទាប់ពីនេះ* Shany និង Horovitz]។

[38] ការចេញផ្សាយព័ត៌មានរបស់អង្គការសហប្រជាជាតិ, "តំណាងពិសេសអង្គការសហប្រជាជាតិ នៃអគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា និងជាអ្នកសាព័ត៌មានពិសេសស្តីពីឯករាជ្យភាពរបស់ចៅក្រម និង មេធាវី សំដែងនូវកង្វល់លើឯករាជ្យភាពរបស់តុលាការ ក្នុងប្រទេសកម្ពុជាក្នុងពេលតែងតាំងតុលាការថ្មីៗនេះ", ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៧។

[39] Shany និង Horovitz] ទំព័រទី២០។

[40] Shany និង Horovitz] ទំព័រទី២០។

[41] សំណើ, កថាខណ្ឌទី៤-១៤។ សូមមើលផងដែរ បណ្តឹងឧទ្ធរណ៍របស់ នួន ជា, កថាខណ្ឌទី២-៦, បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌទី២។

២២. ពេលណាអំពើពុករលួយមានជាប់ពាក់ព័ន្ធនឹងតុលាការ គេតែងតែយល់ឃើញថាជាអំពើពុករលួយរបស់តុលាការ ក្នុងន័យអំពើពុករលួយ ឬការខកខានមិនចាត់វិធានការ (ដូចជាការសូកប៉ាន់) ដែលនាំមកនូវការធ្វើសេចក្តីសម្រេចពុំត្រឹមត្រូវ និងអយុត្តិធម៌[42]។ ទោះបីជាយ៉ាងដូច្នេះក្តី វាជាការយល់ឃើញពុំត្រឹមត្រូវប្រកបដោយគ្រោះថ្នាក់ដែលថាវាដូច្នោះ ឬចាំបាច់ត្រូវដូច្នោះ។

២៣. ការចោទប្រកាន់អំពីអំពើពុករលួយ ដែលជាប្រធានបទនៃបណ្តឹងឧទ្ធរណ៍ទាំងនេះ គឺស្ថិតនៅ ខាងក្រៅដំណើរការខាងតុលាការនៃ អ.វ.ត.ក។ ទង្វើដែលចោទឡើង គឺជាអំពើ "ពុករលួយ" ត្រង់ថា វាជាអំពើដែលប្រើប្រាស់អំណាចពុំត្រឹមត្រូវ ដើម្បីផលប្រយោជន៍ឯកជន (ផលប្រយោជន៍ហិរញ្ញវត្ថុ សម្រាប់បុគ្គលដែលទទួលលុយសំណូក និងការងារសម្រាប់មន្ត្រីបុគ្គលិក)។ ក៏ប៉ុន្តែវាពុំនាំមកនូវ ហើយក៏ពុំពាក់ព័ន្ធ ដល់ការចេញសេចក្តីសម្រេចខាងតុលាការដែលពុំត្រឹមត្រូវ ឬអយុត្តិធម៌ឡើយ។ ពិតណាស់ចៅក្រមដែលទទួលការសូកប៉ាន់នឹងគ្មានឯករាជ្យពីភាគីទាំងឡាយ ឬលម្អៀង និងការសម្រេចឱ្យរួចខ្លួនពីបទឧក្រិដ្ឋ ឬការផ្តន្ទាទោសនៅចំពោះមុខចៅក្រមដែលទទួលសំណូក ដើម្បីធានាឱ្យប្រាកដថាលទ្ធផលមានលក្ខណៈ "ពុំត្រឹមត្រូវជ្រុលហួសហេតុ"[43]។ ធាតុផ្សំនៃ "តុល្យភាពនៃកំលាំង" ឬ សមភាពនីតិវិធីចំពោះភាគីទាំងឡាយ នឹងត្រូវបាត់បង់ដោយពិតប្រាកដ។ ទោះជាដូច្នេះក្តី គ្មានអ្វីនៅក្នុងបណ្តឹងឧទ្ធរណ៍បច្ចុប្បន្ន បានឱ្យតម្រុយថាតុលាការមួយនេះប្រឈមនឹងទង្វើបែបនោះឡើយដោយហេតុថា បើគេសន្និដ្ឋានថាអំពើពុករលួយដែលគេចោទឡើងវាជាការពិតក្តី ក៏អំពើពុករលួយនោះទាក់ទិនទៅនឹងការសូកប្រាក់ដើម្បីរក្សាការងារ

---

[42] របាយការណ៍អំពើពុករលួយពិភពលោក, ទំព័រទី៤។ អង្គការតម្លាភាពអន្តរជាតិ, អង្គការសង្គមស៊ីវិលដែលកំពុងប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយទូទាំងពិភពលោក បញ្ជាក់អំពើពុករលួយពីរប្រភេទដែលប៉ះពាល់ធ្ងន់ធ្ងរដល់តុលាការ៖ ការជ្រៀតជ្រែកនយោបាយក្នុងដំណើការតុលាការដោយរដ្ឋាភិបាល និងអំពើសូកប៉ាន់៖ *ដូចជើងទំព័រខាងលើ*, ទំព័រទី xxii។

[43] Thomas M. DiBiagio, 'អំពើពុករលួយតុលាការ សិទ្ធិទទួលបានការកាត់សេចក្តីដោយយុត្តិធម៌ និងពាក្យស្នើសុំពិនិត្យកំហុសឆ្គងធម្មតា៖ ការទាមទារឱ្យមានភស្តុតាងគួរឱ្យជឿជាក់ច្បាស់លាស់ នៃព្យសនកម្មពិតប្រាកដ ឬគួរតែយើងរកយុត្តិធម៌ក្នុងភាពងងិត?" (១៩៩៨) ២៥ American Journal of Criminal Law 595 ទំព័រ ៦២៧។

របស់មន្ត្រីរដ្ឋបាលមួយចំនួនតែប៉ុណ្ណោះ។ ពោលគឺវាខុសពីការសូកប៉ាន់ដើម្បីរក្សាការសម្រេចខាងតុលាការណាមួយជាក់លាក់។

## ៥.៣ ច្បាប់ជាធរមាន

### *៥.៣.១ គោលការណ៍មូលដ្ឋានក្នុងការរៀបចំដំណើរការតុលាការនេះ*

២៤. តុលាការនេះ ត្រូវបានបង្កើតឡើងតាមរយៈកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ("កិច្ចព្រមព្រៀង")

ដើម្បីនាំខ្លួនយក មកកាត់សេចក្តីនូវមេដឹកនាំជាន់ខ្ពស់របបកម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភធ្ងន់ធ្ងរ ទៅលើច្បាប់កម្ពុជាទាក់ទិននឹងឧក្រិដ្ឋកម្ម ច្បាប់មនុស្សធម៌អន្តរជាតិ និងទំនៀមទម្លាប់ និងសន្ធិសញ្ញាអន្តរជាតិដែលកម្ពុជាបាន ទទួលស្គាល់ ដែលបានប្រព្រឹត្តក្នុងអំឡុងរយៈកាលចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩"[44]។

២៥. កិច្ចព្រមព្រៀងបញ្ជាក់ថាតុលាការនេះត្រូវអនុវត្តយុត្តាធិការរបស់ខ្លួន អនុលោមតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពយុត្តិធម៌ និងនីតិវិធីត្រឹមត្រូវតាមច្បាប់ ដូចបានចែងក្នុងមាត្រា ១៤និង១៥នៃកតិការសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ("ICCPR")[45]។ កិច្ចព្រមព្រៀងត្រូវបានយកមកអនុវត្តដូចច្បាប់នៅកម្ពុជា និងភ្ជាប់តុលាការនេះទៅនឹងកាតព្វកិច្ចតាមផ្លូវច្បាប់[46]។

---

[44] ច្បាប់ អ.វ.ត.ក មាត្រា២។

[45] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹតឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ មាត្រា១២(១), ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣, មាត្រា១២(២) [*បន្ទាប់ពីនេះ* កិច្ចព្រមព្រៀង]។

[46] ច្បាប់ អ.វ.ត.ក, មាត្រា៤៧។

00334703



២៦. កិច្ចព្រមព្រៀងក៏បានចែងថា កិច្ចស៊ើបសួរតាមផ្លូវច្បាប់របស់សហចៅក្រមស៊ើបអង្កេត កំណត់ត្រឹមតែ៖

មេដឹកនាំជាន់ខ្ពស់របបកម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់ បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ច្បាប់ មនុស្សធម៌អន្តរជាតិនិងទំនៀមទម្លាប់ និងអនុសញ្ញាអន្តរជាតិដែលកម្ពុជា បានទទួលស្គាល់ ដែលបានប្រព្រឹត្តអំឡុងរយៈកាលចាប់ពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩[47]។

២៧. កិច្ចព្រមព្រៀងនេះ បានរំពឹងគិតទុកថា នីតិវិធីរបស់តុលាការនេះ ត្រូវអនុលោមតាមច្បាប់កម្ពុជា[48]។ ត្រង់ចំណុចដែលនីតិវិធីមាន ស្រាប់ពុំពាក់ព័ន្ធនឹងបញ្ហាជាក់លាក់ណាមួយ ឬ ប្រសិនបើមានភាពមិនច្បាស់លាស់ ពាក់ព័ន្ធនឹងការបកស្រាយ ឬការយកមកអនុវត្ត ឬ ប្រសិនបើមានបញ្ហាចោទទាក់ទិននឹងភាព សមស្របទៅនឹងបទដ្ឋានអន្តរជាតិ គេត្រូវរកការណែនាំក្នុងវិធាននីតិវិធី ដែលបានបង្កើតឡើង ក្នុងកម្រិតអន្តរជាតិ[49]។

### *៥.៣.២ អំណាចតាមផ្លូវច្បាប់របស់សហចៅក្រមស៊ើបអង្កេត*

#### *៥.៣.២.១ ទូទៅ*

២៨. ខណៈពេលកិច្ចព្រមព្រៀង និងច្បាប់ អ.វ.ត.ក ជាឯកសារដំបូងរបស់តុលាការនេះ វិធានផ្ទៃក្នុងបញ្ចូលច្បាប់នីតិវិធីធរមាន ចំពោះមុខតុលាការនេះ ដូចដែលបានកំណត់ដោយមាត្រា១២(១) នៃកិច្ចព្រមព្រៀង និងមាត្រា២០ ២៣ និង៣៣ នៃច្បាប់ អ.វ.ត.ក[50]។ អនុលោមតាមវិធានទាំងនោះ ក្នុងចំណោមភារកិច្ចជាច្រើន សហចៅក្រមស៊ើបអង្កេតមានអំណាច(១) បំពេញកិច្ចស៊ើបសួរ និង(២) ចាត់វិធានការណ៍ជាក់លាក់ទាក់ទិននឹងទង្វើដែលជ្រៀតជ្រែករំខានដល់កិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ។

---

[47] កិច្ចព្រមព្រៀង, មាត្រា៥(៣)។

[48] កិច្ចព្រមព្រៀង, មាត្រា១២(១)។

[49] កិច្ចព្រមព្រៀង, មាត្រា១២(១); ច្បាប់ អ.វ.ត.ក, មាត្រា២០។

[50] វិធាន, បុព្វកថា។

### *៥.៣.២.២ អំណាចក្នុងការស៊ើបសួរ*

២៩. ទីមួយ ទាក់ទិននឹងអំណាចអនុវត្តកិច្ចស៊ើបសួរ វិធាន៥៥ (១០) ផ្តល់សិទ្ធិដល់ជនត្រូវចោទក្នុងការស្នើសុំ "គ្រប់ពេលវេលានៃការស៊ើបសួរ" ទៅកាន់សហចៅក្រមស៊ើបអង្កេតឱ្យ "ចេញដីកា ឬបំពេញកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថាមានប្រយោជន៍ដល់ការស៊ើបសួរ"។ មាត្រា៥៨(៦) បានចែងទៀតថា ក្នុងអំឡុងពេលស៊ើបសួរ ជនត្រូវចោទក្នុងចំណោមការងារជាច្រើន អាចស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេត "ប្រមូលភស្តុតាង"។

៣០. ក្នុងការស៊ើបសួរខាងតុលាការ សហចៅក្រមស៊ើបអង្កេតក៏ត្រូវបានផ្តល់សិទ្ធិអំណាចឱ្យចាត់ "វិធានការណ៍ស៊ើបសួរទាំងឡាយណាដែលនាំទៅដល់ការលាតត្រដាងការពិត"[51]។ ក្នុងគ្រប់ករណីទាំងអស់ ពួកគេត្រូវបំពេញកិច្ចស៊ើបសួរដោយមិនលម្អៀង មិនថាភស្តុតាងនោះជាភស្តុតាងដោះ ឬដាក់បន្ទុកឡើយ។ ចុងក្រោយ ពួកគេអាច"ស្វែងរកព័ត៌មាន ឬជំនួយពីរដ្ឋទាំងឡាយ អង្គការសហប្រជាជាតិ ឬអង្គការអន្តររដ្ឋាភិបាល ឬអង្គការមិនមែនរដ្ឋាភិបាល ឬប្រភពផ្សេងៗដែលពួកគេយល់ថាសមស្រប"[52]។ មាត្រា២៣ នៃច្បាប់ អ.វ.ត.ក ចែងថា ក្នុងការអនុវត្តន៍កិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេត "អាចស្វែងរកជំនួយពីរាជរដ្ឋាភិបាលកម្ពុជា ប្រសិនបើជំនួយនោះមានប្រយោជន៍ដល់ការស៊ើបសួរ ហើយជំនួយនោះត្រូវតែបានផ្តល់ឱ្យ"។

៣១. វិធានផ្ទៃក្នុងពុំបានកំណត់ច្បាស់លាស់អំពីនិយមន័យនៃពាក្យថា "ការស៊ើបសួរ" ឡើយ។ ប៉ុន្តែអង្គបុរេជំនុំជម្រះបានកំណត់ថា អត្ថន័យនៃពាក្យនេះអាចសន្និដ្ឋានបាន[53]។ អង្គបុរេជំនុំជម្រះយល់ឃើញថា៖

---

[51] វិធាន, វិធាន៥៥(៥)។

[52] ដូចជើងទំព័រខាងលើ, វិធាន៥៥(៥)។

[53] *រឿងក្តី ខៀវ សំផន,* សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ, ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៩, A190/I/20, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ១១), កថាខណ្ឌទី២៣។

00334705



[សំណើសុំឱ្យមានកិច្ចស៊ើបសួរ គួរត្រូវបានបកស្រាយថាជា សំណើសុំឱ្យមានការអនុវត្តន៍សកម្មភាពដោយសហចៅក្រមស៊ើបអង្កេត ឬតាមរយៈការធ្វើប្រតិភូកម្មអំណាច ដោយអ្នកស៊ើបអង្កេត អ.វ.ត.ក ឬមន្ត្រីនគរបាលយុត្តិធម៌ ដោយមានគោលបំណងប្រមូលព័ត៌មានដែលនាំទៅដល់ការលាតត្រដាងការពិត[54]។]

៣២. អំណាចរបស់សហចៅក្រមស៊ើបអង្កេតក្នុងការអនុវត្តកិច្ចស៊ើបសួរ ត្រូវបានកំណត់ក្រោមវិធានផ្ទៃក្នុងត្រឹមតែ "អង្គហេតុដែលបានលើកឡើងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរឬដីកាសន្និដ្ឋានបន្ថែម"[55]។ អំណាចរបស់ពួកគេត្រូវបានកំណត់ត្រឹមតែយុត្តាធិការក្រោមមាត្រា២ នៃច្បាប់ អ.វ.ត.ក ដូចដែលបានបញ្ជាក់ខាងលើ។[56]

### *៥.៣.២.៣ អំណាចក្នុងការដាក់ទណ្ឌកម្ម*

៣៣. ទីពីរ វិធានផ្ទៃក្នុងចែងថា "អ.វ.ត.ក [រួមទាំងសហចៅក្រមស៊ើបអង្កេត] អាចដាក់ទណ្ឌកម្ម ឬបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ច នូវបុគ្គលទាំងឡាយណាដែលមានចេតនាជ្រៀតជ្រែក រំខានដល់កិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ"[57]។ ហេតុនេះ ដើម្បីដាក់ទោសទណ្ឌបាន ទាល់តែ (១) ជនម្នាក់ធ្វើការជ្រៀតជ្រែករំខានដល់កិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ និង (២) ការជ្រៀតជ្រែករំខាននេះ ត្រូវតែបានធ្វើឡើងដោយចេតនា។

៣៤. ការដាក់ទោសទណ្ឌក្រោមវិធាន ៣៥ អាចត្រូវបានផ្ដួចផ្ដើមឡើង បន្ទាប់ពីអាជ្ញាធរតុលាការដែលពាក់ព័ន្ធមានហេតុផលគួរជឿបានថា ជនម្នាក់អាចប្រហែលជាបានប្រព្រឹត្តអំពើដែលនាំឈានទៅដល់ការជ្រៀតជ្រែករំខានដល់កិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ។

---

[54] *ដូចជើងទំព័រខាងលើ,* កថាខណ្ឌទី២៨។

[55] វិធាន, វិធាន៥៥(២)។

[56] ស្រដៀងគ្នាដែរ ប្រព័ន្ធរបស់ប្រទេសបារាំងកំណត់ព្រំដែនសិទ្ធិអំណាចចៅក្រមស៊ើបសួរ ចំពោះបទចោទប្រកាន់ដូចមានចែងកំណត់នៅក្នុងបទចោទអំពីកិច្ចស៊ើបសួរ, ក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង, មាត្រា៧៩-១០០។

[57] ដូចជើងទំព័រខាងលើ, វិធាន ៣៥(១)។

00334706



តាមរយៈការជឿជាក់ច្ចេះ សមត្ថកិច្ចអាច (១) ដោះស្រាយបញ្ហាដោយសង្ខេប (២) អនុវត្តកិច្ចស៊ើបសួរបន្ថែមទៀត ឬ (៣) បញ្ជូនបញ្ហានេះទៅកាន់អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋាភិបាលកម្ពុជា ឬអង្គការសហប្រជាជាតិ[58]។ ច្បាប់កម្ពុជាយកមកអនុវត្ត "ទាក់ទិននឹងការដាក់ទោសទណ្ឌ" ប្រឆាំងនឹងជនដែលត្រូវបានគេរកឃើញថារំលោភវិធាន៣៥[59]។

### *៥.៣.២.៤ យន្តការសម្រាប់ការប្ដឹងជំទាស់*

៣៥. បន្ថែមពីលើនេះ វិធានផ្ទៃក្នុងក៏ផ្ដល់យន្តការសម្រាប់បណ្ដឹងជិតចិត្តចំពោះចៅក្រម អ.វ.ត.ក ក្នុងនោះរួមមានទាំង សហចៅក្រមស៊ើបអង្កេតផងដែរ។ អនុលោមតាមវិធាន៣៤ ភាគីទាំងឡាយអាចដាក់ពាក្យសុំដាក់បណ្ដឹងជិតចិត្តចំពោះចៅក្រមណាមួយ ក្នុងករណីទាំងឡាយដែល (១) ចៅក្រមមានផលប្រយោជន៍ផ្ទាល់ខ្លួន ឬហិរញ្ញវត្ថុ ឬ(២) ពាក់ព័ន្ធនឹងករណីដែលចៅក្រមមាន ឬធ្លាប់មានការពាក់ព័ន្ធដែលអាចប៉ះពាល់ពិតប្រាកដដល់ភាពអនាគតិរបស់ចៅក្រមរូបនោះ ឬអាចបង្កើតឱ្យមានភាពលម្អៀង[60]។ ភាគីមួយដែលដាក់ពាក្យសុំប្ដឹងជិតចិត្តចំពោះចៅក្រមណាមួយ ត្រូវបញ្ជាក់ឱ្យច្បាស់អំពីមូលដ្ឋានសម្រាប់បណ្ដឹងជិតចិត្ត និងផ្ដល់ភស្តុតាងគាំទ្រ[61]។

### *៥.៣.៣ អំណាចដែលទទួលស្គាល់ថា "ជាអំណាចមានពីធម្មជាតិ" ដោយតុលាការផ្សេងៗគឺជាអំណាចនិម្មិតរូបនៅ អ.វ.ត.ក*

៣៦. សាលាក្ដីអន្តរជាតិពិសេសផ្សេងៗ ដូចជាសាលាក្ដីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ICTY)[62] និងសាលាក្ដីព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ៉្វាន់ដា("ICTR")[63] និង

---

[58] ដូចជើងទំព័រខាងលើ, វិធាន៣៥(២)។

[59] *ដូចជើងទំព័រខាងលើ,* វិធាន៣៥(៥)។

[60] ដូចជើងទំព័រខាងលើ, វិធាន៣៤(២)។

[61] ដូចជើងទំព័រខាងលើ, វិធាន៣៤(៣)។

[62] វិធាន ICTY នៃនីតិវិធី និងភស្តុតាង, វិធាន១៥(ក)។

[63] ដូចជើងទំព័រខាងលើ, វិធាន១៥(ក)។

សៀរ៉ាឡេអូន ("SCSL")[64] និងស្ថាប័នតុលាការអចិន្ត្រៃយ៍ ដូចជាតុលាការព្រហ្មទណ្ឌអន្តរជាតិ ("ICC")[65] និងតុលាការយុត្តិធម៌អន្តរជាតិ ("ICJ")[66] បានទទួលស្គាល់អំណាចពីធម្មជាតិ ដែលចេញមកពីតួនាទីខាងតុលាការរបស់ពួកគេ ដើម្បីចាត់ចែងកិច្ចដំណើរការនីតិវិធីដើម្បីសម្រេចឱ្យបានយុត្តិធម៌[67]។ តុលាការយុត្តិធម៌អន្តរជាតិកាលនៅក្នុងសំណុំរឿង Northern Cameroons ក្នុងឆ្នាំ១៩៦៣ និងក្នុងសំណុំរឿង Nuclear Tests ក្នុងឆ្នាំ ១៩៧៤ បានបញ្ជាក់អំពីអត្ថិភាពនៃយុត្តាធិការពីធម្មជាតិនៃស្ថាប័នតុលាការអន្តរជាតិ "ដែលជម្រុញឱ្យខ្លួនអនុវត្តសកម្មភាព ដូចដែលអាចត្រូវបានគេស្នើសុំដើម្បីធានាឱ្យប្រាកដថាការអនុវត្តន៍យុត្តាធិការរបស់ខ្លួនទៅលើអង្គសេចក្តីមិនត្រូវបានធ្វើឱ្យគេអស់សង្ឃឹម ប្រសិនបើ ឬនៅពេលត្រូវបានបង្កើតមានសមត្ថកិច្ច ហើយម្យ៉ាងទៀត ដើម្បីយកចិត្តទុកដាក់ត្រួតពិនិត្យការដោះស្រាយតាមលំដាប់លំដោយនៃបញ្ហាដែលកំពុងមានជម្លោះ សំដៅធានាបាននូវការគោរព "ដែនកំណត់ពីធម្មជាតិទៅលើការអនុវត្តន៍តួនាទីខាងតុលាការ" និងដើម្បី "រក្សានូវចរិកលក្ខណៈផ្នែកតុលាការ"[68]។

៣៧. អំណាចពីធម្មជាតិទាំងនេះមានការពាក់ព័ន្ធជាពិសេស នៅពេលសាលាក្តីដោះស្រាយបញ្ហានីតិវិធីចំពោះបញ្ហាទាំងនេះគឺដើម្បីធានាថា ការជំនុំជម្រះក្តីមានភាពយុត្តិធម៌ និងឆាប់

---

[64] វិធាន SCSL នៃនីតិវិធី និងភស្តុតាង, វិធាន១៥(ក)។

[65] វិធាន ICC នៃនីតិវិធី និងភស្តុតាង, វិធាន៣៤(១)។

[66] លក្ខន្តិកៈរបស់ ICJ, មាត្រា១៧(២)។

[67] ជាទូទៅសូមមើល ទាក់ទងនឹងអំណាចផ្ទាល់ខ្លួន៖ *រឿងក្តី Northern Cameroons* (របាយការណ៍ ICJ ឆ្នាំ១៩៦៣, ទំព័រ ២៩) និង *The Nuclear Test Case* (របាយការណ៍ ICJ ឆ្នាំ១៩៧៤, ទំព័រទី២៥៩-២៦០, កថាខណ្ឌ២៣), ភ្ជាប់ដោយ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTY ក្នុង*រឿងក្តីរដ្ឋអាជ្ញា តទល់ Blaskic*, សំណុំរឿង IT-95-14-AR108bis, សេចក្តីសម្រេចលើសំណើរបស់ សាធារណៈរដ្ឋ Croatia សម្រាប់ការពិនិត្យសេចក្តីសម្រេចរបស់ អង្គជំនុំជម្រះ II ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៩៧, ថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៩៧, ជើងទំព័រ២៧ កថាខណ្ឌទី២៥។

[68] Northern Cameroons, សេចក្តីសម្រេច, របាយការណ៍របស់ I.C.J ឆ្នាំ១៩៦៣, ទំព័ទី២៩; យោងក្នុង *រឿងក្តីរដ្ឋអាជ្ញា តទល់ Beqa Beqaj*, សំណុំរឿងលេខ IT-03-66-T-R77, សេចក្តីសម្រេចលើ ការចោទប្រកាន់ពីការមាក់ងាយចៅក្រម, ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៥, កថាខណ្ឌ១១[*បន្ទាប់ពីនេះ,* សាលក្រមលើការចោទប្រកាន់ពីការមាក់ងាយចៅក្រមក្នុងរឿងក្តី Beqa Beqaj]។

របស់ស[69]។ អំណាចទាំងនេះត្រូវបានបញ្ជាក់ជាផ្នែក នៅក្នុងឆន្ទានុសិទ្ធិដែលបានប្រគល់ទៅឱ្យសាលាក្តីនានា ដើម្បីតាក់តែងវិធាននីតិវិធីរបស់ពួកគេ និងដើម្បីបំពេញការងារអ្វីដែលចាំបាច់ ដើម្បីរៀបចំ និងដឹកនាំការជំនុំជម្រះក្តី[70]។

៣៨. លទ្ធិអំណាចពីធម្មជាតិ ត្រូវបានដាក់ឱ្យអនុវត្តទូទៅដោយយោងតាមអំណាចរបស់តុលាការក្នុងការដោះស្រាយទង្វើដែលជ្រៀតជ្រែករំខាន ដល់កិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ[71]។ អំណាចរបស់សាលាក្តីមួយ ក្នុងការដាក់ទោសទណ្ឌ ទង្វើ "ដែលមានចេតនារាំងស្ទះបន្ទុចបង្អាក់ រើសអើង ឬបំពារបំពានកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ"[72] គឺមានសារៈសំខាន់ក្នុងការធានាថា ការអនុវត្តន៍យុត្តាធិការពុំត្រូវបានធ្វើឱ្យរាំងស្ទះ ហើយ

---

[69] *រឿងក្តីរដ្ឋអាជ្ញា តទល់ Delalic និងអ្នកផ្សេងទៀត,* សំណុំរឿងលេខ IT-96-21-A, យោបល់ដាច់ពីគ្នារបស់ចៅក្រម Hunt ស្តីពី សំណើដោយ Esad Landzo សុំឱ្យរក្សាទុក និងផ្តល់ភស្តុតាង, អង្គជំនុំជម្រះIII, ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៩៩, កថាខណ្ឌ២៥ [*បន្ទាប់ពីនេះ* រឿងក្តី Delalic]។

[70] *រឿងក្តីរដ្ឋអាជ្ញា តទល់ Blaškic,* សំណុំរឿងលេខ IT-95-14-AR108*bis*, សេចក្តីសម្រេចលើសំណើរបស់សាធារណរដ្ឋ Croatia សម្រាប់ការពិនិត្យឡើងវិញនូវសេចក្តីសម្រេចរបស់ អង្គជំនុំជម្រះ II ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៩៧, ថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៩៧ (កថាខណ្ឌ២៥) [*បន្ទាប់ពីនេះ* សេចក្តីសម្រេចលើដីការឿងក្តី Blaskic]។ សេចក្តីសម្រេចលើដីការឿងក្តី Blaškic ត្រូវបានភ្ជាប់ក្នុង *រឿងក្តីរដ្ឋអាជ្ញា តទល់Tadic,* សំណុំរឿង IT-94-1-A, សេចក្តីសម្រេច, ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩, កថាខណ្ឌ៣២២។

[71] សេចក្តីសម្រេចលើដីកា Blaskic, ជើងទំព័រ២៧; *រឿងក្តីរដ្ឋអាជ្ញា តទល់Tadic,* សំណុំរឿង IT-94-1-A-R77, សេចក្តីសម្រេចលើការចោទប្រកាន់ពីការមាក់ងាយប្រឆាំងនឹងមេធាវីមុន ឈ្មោះ Milan Vujin, ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០០ [*បន្ទាប់ពីនេះ* សេចក្តីសម្រេចលើការមាក់ងាយក្នុងរឿងក្តី Tadic]។ សូមមើលផងដែរ សេចក្តីសម្រេចលើការមាក់ងាយ ក្នុងរឿងក្តី Beqa Beqai, កថាខណ្ឌ៩។

[72] សេចក្តីសម្រេចលើការមាក់ងាយក្នុងរឿងក្តី Tadic, កថាខណ្ឌ១៦, ស្រង់អត្ថបទពីរបាយការណ៍របស់ (UK) គណៈកម្មាធិការស្តីពីការមាក់ងាយតុលាការ, បោះពុម្ពក្នុងឆ្នាំ១៩៧៤, ដែល "ត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយ ថាជាការវាយតម្លៃដ៏ត្រឹមត្រូវមួយ នៃគោលបំណងនិងដែនកំណត់នៃច្បាប់មាក់ងាយ នៅក្នុង common law ដូចដែលត្រូវបានបង្កើតឡើងរាប់សតវត្សមកហើយ"។

តួនាទីផ្នែកតុលាការរបស់ខ្លួនត្រូវបានការពារ[73]។ ការសំខាន់នោះ គឺអំណាចពីធម្មជាតិជម្រុញឱ្យតុលាការអាចធានាបានថាកិច្ចដំណើរការនីតិវិធីមានភាពយុត្តិធម៌[74]។

៣៩. ថ្វីបើយ៉ាងនេះ អំណាចពីធម្មជាតិទាំងនេះត្រូវបានចងក្រងជាវិធាននៅ អ.វ.ត.ក ស្របតាមការអនុវត្តន៍យុត្តាធិការច្បាប់ស៊ីវិល[75]។ អំណាចនៃតុលាការនេះ "ក្នុងការដាក់ទោសទណ្ឌជន ទាំងឡាយណាដែលមានចេតនាជ្រៀតជ្រែករំខានដល់កិច្ចការរដ្ឋបាលនៃអង្គជំនុំជម្រះ"[76] ត្រូវបានទទួលស្គាល់ក្នុងឯកសារមូលដ្ឋានរបស់តុលាការនេះ។ វិធានផ្ទៃក្នុង ដូចដែលបានពិភាក្សា គឺបានប្រគល់សិទ្ធិអំណាចដល់ចៅក្រមតុលាការនេះ ឱ្យចាត់វិធានការណ៍ពាក់ព័ន្ធនឹងទង្វើដែលជ្រៀតជ្រែករំខានដល់កិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ (វិធាន៣៥) និងមាត្រា៣៣ នៃច្បាប់ អ.វ.ត.ក និងវិធាន២១(១) បានប្រគល់សិទ្ធិអំណាចដល់ស្ថាប័នទាំងអស់នៃតុលាការនេះ ក្នុងនោះរួមមានសហចៅក្រមស៊ើបអង្កេត ដើម្បីធានាបានថា កិច្ចដំណើរការនីតិវិធីនៅចំពោះមុខតុលាការ ក្នុងចំណោមបញ្ហាផ្សេងៗ មានភាព "យុត្តិធម៌"[77]។ ដោយសារតែមកពីការចងក្រងអំណាចពីធម្មជាតិនេះ ទើបការទទួលស្គាល់អំណាចទាំង នេះនៅ អ.វ.ត.ក ពុំមានភាពចាំបាច់ និងមិនពាក់ព័ន្ធ។

---

[73] ដូចដើងទំព័រខាងលើ, កថាខណ្ឌ១៨។

[74] *រឿងក្តីរដ្ឋអាជ្ញា តទល់ Blagojevic,* IT-02-60-AR73.4, ហេតុផលដែលត្រូវបានពិនិត្យផ្ទៀងផ្ទាត់ និងហេតុផលជាសាធារណៈ សម្រាប់សេក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ ដោយ Vidje Blagojevic ដើម្បីជំនួសក្រុមការពារក្តីរបស់គាត់, ចុះថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០០៣, កថាខណ្ឌ៧៖ "អំណាចផ្ទាល់ខ្លួនតែមួយគត់ដែលអង្គជំនុំជម្រះមាន គឺត្រូវធានាថាការកាត់សេចក្តីជនជាប់ចោទមានយុត្តិធម៌"។

[75] សេចក្តីសម្រេចលើការមាក់ងាយក្នុងរឿងក្តី Tadic, កថាខណ្ឌ១៧។ ឧទាហរណ៍, ក្រមព្រហ្មទណ្ឌអាល្លឺម៉ង់ ដាក់ទណ្ឌកម្មជាគោលការណ៍ដល់ជនល្មើសទាំងឡាយណាដែលញុះញង់ឱ្យសាក្សីផ្តល់ចម្លើយខ្លែងក្លាយ *និងក្រមព្រហ្មទណ្ឌបារាំងថ្មី* ដាក់ទណ្ឌកម្មដល់ជនទាំងឡាយណាដែលដាក់សម្ពាធឱ្យសាក្សីផ្តល់ភស្តុតាងខ្លែងក្លាយ ឬនៅស្ងៀមិនព្រមផ្តល់ភស្តុតាងបន្ថែម -- សូមមើល សេចក្តីសម្រេចលើការមាក់ងាយក្នុងរឿងក្តី Tadic, ជើងទំព័រ២០។

[76] សេចក្តីសម្រេចលើការមាក់ងាយក្នុងរឿងក្តី Tadic, កថាខណ្ឌ១៦, ២៦។ សូមមើលផងដែរ *រឿងក្តីរដ្ឋអាជ្ញា តទល់ Delalic និងអ្នកផ្សេងទៀត* IT-96-21។ សេចក្តីសម្រេចលើពាក្យសុំដកខ្លួនជាមេធាវី ដោយសាតែទំនាស់ផលប្រយោជន៍, ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ១៩៩៩។ ត្រូវបានយោងក្នុងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ២៤។

[77] វិធាន, វិធាន២១(១)។

### *៥.៣.៤ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនត្រូវចោទ ដែលតុលាការនេះជាអ្នកជំនុំជម្រះ*

៤០. គោលការណ៍សាលាក្តីយុត្តិធម៌ ឯករាជ្យ និងមិនលម្អៀង គឺត្រូវបានផ្តល់សិទ្ធិអំណាច ជាមូលដ្ឋាន និងជាសាកលដោយច្បាប់សិទ្ធិមនុស្សអន្តរជាតិ[78] និងត្រូវបានឆ្លុះបញ្ចាំងក្នុងឯកសារបង្កើតតុលាការនេះ។ ស្របតាមស្មារតីនៃកិច្ចព្រមព្រៀង និងច្បាប់ អ.វ.ត.ក និងយក "ភាពច្បាស់លាស់ជាក់លាក់ពីធម្មជាតិ" នៃតុលាការនេះមកពិចារណា វិធាន ២១(១) បានចែងច្បាស់អំពី "គោលការណ៍មូលដ្ឋាន" ក្នុងនោះបានចែងថា កិច្ចដំណើរការនីតិវិធីនៅចំពោះមុខតុលាការនេះ ត្រូវតែមាន "យុត្តិធម៌ និងគោរពចំពោះមុខ"[79] ហើយបានចែងថារាល់ឯកសារមូលដ្ឋានទាំងអស់របស់តុលាការនេះ(ក្នុងនោះរួមមានវិធានផ្ទៃក្នុង និងសេចក្តីណែនាំអនុវត្តន៍) ត្រូវតែបកស្រាយ "ដើម្បីការពារជានិច្ចនូវ ផលប្រយោជន៍នៃជនត្រូវចោទ និងជនរងគ្រោះ និងសំដៅធានា [...] តម្លាភាពនៃកិច្ចដំណើរការនីតិវិធី"[80]។

៤១. ដោយដកស្រង់ចេញពីមាត្រា៣៥(ថ្មី)នៃច្បាប់ អ.វ.ត.ក អង្គបុរេជំនុំជម្រះបានកត់សម្គាល់ឃើញថាជនត្រូវចោទនៅចំពោះមុខតុលាការនេះ ប្រើប្រាស់សិទ្ធិក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ "ចាប់តាំងពីដើមដំបូងនៃកិច្ចស៊ើបសួរខាងតុលាការ"[81]។ ក្នុងអត្ថន័យស្រដៀងគ្នានេះ តុលាការព្រហ្មទណ្ឌអន្តរជាតិ ("ICC") ដែលដំណាក់កាលស៊ើបអង្កេតរបស់គេពុំខុសគ្នាជាដុំកំភួនទៅនឹងអ.វ.ត.ក នេះ បានកំណត់ថាការធានាឲ្យមានការជំនុំជម្រះប្រកបដោយយុត្តិធម៌ គឺពុំកំណត់ត្រឹមតែការជំនុំជម្រះតែមួយមុខនោះទេ ប៉ុន្តែ

---

[78] ត្រូវបានចែងក្នុងលិខិតុបករណ៍ ដូចជា សេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្ស (មាត្រា១០ និង២៣), កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ (មាត្រា១៤(១)), និងអនុសញ្ញាតំបន់ ដូចជា កតិកាសញ្ញាអឺរុបស្តីពីសិទ្ធិមនុស្ស (មាត្រា៦)។

[79] វិធាន, វិធាន២១(១)(ក)។

[80] *ដូចដើងទំព័រខាងលើ,* វិធាន២១(១)។

[81] រឿងក្តី នួន ជា, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ចំពោះការចាត់តាំងអ្នកជំនាញ, ឯកសារលេខ D54/V/6, ERN 00233628-00233644, កថាខណ្ឌ២៥។

សំដៅទៅដល់ដំណើរការទាំងឡាយណាដែលកើតមានឡើងមុនការជំនុំជម្រះមកដល់ និង ទៅលើគ្រប់ផ្នែកនៃកិច្ចដំណើរការនីតិវិធីទាំងអស់[82]។

៤២. អ្វីដែលមានសារៈសំខាន់ដល់សិទ្ធិ ក្នុងការជំនុំជម្រះប្រកបដោយយុត្តិធម៌នៃជនត្រូវចោទទាំងអស់ គឺជាសិទ្ធិទទួលការជំនុំជម្រះដោយតុលាការឯករាជ្យ និងមិនលម្អៀង[83]។ ទស្សនាទាននេះបានកំណត់ថា ចៅក្រម អ.វ.ត.ក ទាំងអស់ ត្រូវឯករាជ្យក្នុងការបំពេញតួនាទី និងមិនត្រូវទទួលយក ឬស្វែងរកការណែនាំពីប្រភពណាមួយឡើយ[84]។ ការធានានេះត្រូវបានផ្តល់សុពលភាពដោយមាត្រា៣៣ នៃច្បាប់ អ.វ.ត.ក ដែលយកគំរូតាមមាត្រា១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ។ មាត្រា ១៤ ចែងថា ក្នុងការកំណត់បទចោទឧក្រិដ្ឋកម្មណាមួយ "មនុស្សរាល់គ្នាត្រូវមានសិទ្ធិទទួលបានសវនាការដោយយុត្តិធម៌ និងជាសាធារណៈ ដោយសាលាក្តីមួយដែលមានសមត្ថភាពឯករាជ្យ និងមិនលម្អៀង ដែលបង្កើតឡើងដោយច្បាប់"[85]។

៤៣. ការធានាដូចៗគ្នា ក៏មានដែរនៅក្នុងលិខិតូបករណ៍អន្តរជាតិផ្សេងៗ ក្នុងនោះរួមមានអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ("ECHR")[86] អនុសញ្ញាអន្តរអាមេរិកស្តីពីសិទ្ធិមនុស្ស

---

[82] *ស្ថានភាពក្នុងសាធារណៈរដ្ឋប្រជាធិបតេយ្យ Congo, ក្នុងរឿងក្តីរដ្ឋអាជ្ញា តទល់ Thomas Lubanga Dyilo,* សេចក្តី សម្រេចលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹង សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ I មានចំណងជើង ថា "សេចក្តីសម្រេចលើផលវិបាកនៃការមិនបង្ហាញភស្តុតាងដាក់បន្ទុក ដែលមានចែងក្នុង មាត្រា៥៤ (៣)(ង)៖ ការព្រមព្រៀង និងពាក្យសុំផ្អាកការកាត់សេចក្តីជនជាប់ចោទ ភ្ជាប់ជាមួយនឹងបញ្ហា ផ្សេងទៀតដែលបានលើកឡើងនៅឯកិច្ចប្រជុំរៀបចំតុលាការ ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៨, ICC-01/04-01/06 OA 13, ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៨, យោបល់ដាច់ដោយឡែករបស់ចៅក្រម Georghios M. Pikis, កថាខណ្ឌ៤៤។

[83] *រឿងក្តី Gonzalez de Rio តទល់ Peru,* ការទំនាក់ទំនងលេខ 263/1987, U.N. Doc. CCPR/C/46/D/263/1987, ចុះថ្ងៃទី28 ខែតុលា ឆ្នាំ1992។

[84] កិច្ចព្រមព្រៀង, មាត្រា១៤, កថាខណ្ឌ១។

[85] ICCPR, មាត្រា១៤, កថាខណ្ឌ១។

[86] ECHR, មាត្រា៦(១)។

00334712



("IACHR")[87] និងធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិប្រជាជន និងសិទ្ធិមនុស្ស ("ACHPR")[88]។ រដ្ឋធម្មនុញ្ញកម្ពុជាក៏បានចែងអំពីតុលាការមិនលម្អៀង និងឯករាជ្យផងដែរ[89]។

### *៥.៣.៤ ការវិនិច្ឆ័យអំពីភាពលម្អៀង គឺស្ថិតនៅជុំវិញបញ្ហាថាភាពលម្អៀងដោយពិតប្រាកដ ឬដោយការយល់ឃើញ*

៤៤. ដើមបណ្តឹងឧទ្ធរណ៍បានលើកឡើងថា ការចោទប្រកាន់ពីអំពើពុករលួយអាចគម្រាម កំហែងដល់សិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបាននូវការកាត់សេចក្តីដោយយុត្តិធម៌ នៅចំពោះមុខតុលាការឯករាជ្យនិងមិនលម្អៀង[90]។ ចំពោះការអះអាងក្នុងការធ្វើការថ្លឹងថ្លែងអំពីផ្លូវច្បាប់នេះ ការលើកឡើងដែលថាអាចមានការគម្រាមកំហែងដល់ភាពអនាគតិនិងឯករាជ្យភាពនោះ ត្រូវតែមានចរិតលក្ខណៈគ្រប់គ្រាន់ក្នុងការច្រានចោលនូវការសន្មតដែលពាក់ព័ន្ធនឹងភាពអនាគតិ និង/ឬ ឯករាជ្យភាពរបស់ចៅក្រមម្នាក់ (ឬច្រើននាក់) ហេតុដូច្នេះហើយ វាត្រូវមានលក្ខណៈគ្រប់គ្រាន់ក្នុងការបដិសេធថា ជនល្មើសទទួលបាននូវសវនាការដោយយុត្តិធម៌។ វិធីដែលជាជម្រើសម្យ៉ាងទៀតក្នុងការគ្រោងជាសំណួរថាតើមានការលម្អៀង ឬទេនោះ គឺថាតើការលើកឡើងអំពីអំពើពុករលួយបង្កើតនូវក្តីព្រួយបារម្ភអំពីភាពអនាគតិ និង/ឬ ឯករាជ្យភាពដែរឬទេ។ ថាតើមានភាពពាក់ព័ន្ធគ្នារវាងអំពើពុករលួយដែលត្រូវបានចោទប្រកាន់ និងការប្រព្រឹត្តរបស់ចៅក្រមនៅពេលសវនាការដែរឬទេ

[87] IACHR, មាត្រា៨(១)។

[88] ACHPR, មាត្រា៧(១)។

[89] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, មាត្រា១២៨។

[90] នួន ជា បានចោទប្រកាន់ថា ការចោទប្រកាន់ពីបទពុករលួយ "អាចគំរាមកំហែងដល់សិទ្ធិ [របស់គាត់] ចំពោះឯករាជ្យភាព និងភាពមិនសំអៀងនៃការកាត់សេចក្តី ការស៊ើបអង្កេត និងសវនាការ"៖ ដូចគ្នានេះដែរ អៀង សារី អះអាងថាភាពយុត្តិធម៌នៃដំណើរការនីតិវិធីតុលាការ អាចប៉ះពាល់ដោយការចោទប្រកាន់ពីបទពុករលួយ។ បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ៤១។

ក៏ដូចជាភាពលម្អៀងពិតប្រាកដរបស់ចៅក្រម ដែលកើតចេញមកពីការប្រព្រឹត្តក្រៅផ្លូវតុលាការរបស់ចៅក្រមទាំងនោះដែរឬទេ[91]។

៤៥. នៅក្នុងប្រព័ន្ធច្បាប់ទ្វីបអឺរ៉ុប លក្ខខណ្ឌតម្រូវថាចៅក្រមមិនគ្រាន់តែ ត្រូវមានភាពអនាគតិពិតប្រាកដប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវសំដែងឲ្យឃើញនូវភាពអនាគតិនោះផងដែរ[92]។ តុលាការសិទ្ធិមនុស្សអឺរ៉ុប តម្រូវការក្នុងការប្តឹងជិតចិត្តចៅក្រមណាមួយ គឺថាតើកង្វះភាពអនាគតិជាអត្តនោម័ត ឬកង្វះភាព អនាគតិជាសត្យានុម័តឬទេ[93]។ នៅក្នុងរឿងក្តី Furundzija តុលាការឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់អតីតយូហ្គោស្លាវី បានលើកឡើងថាចៅក្រមមិនគ្រាន់តែត្រូវចៀសឲ្យផុតពីភាព លម្អៀងជាអត្តនោម័តប៉ុណ្ណោះទេ តែថែមទាំងមិនត្រូវមានអ្វីមួយនៅជុំវិញកាលៈទេសៈ ដែលនាំឲ្យកើតមានភាពលម្អៀងយ៉ាងពិតប្រាកដនោះដែរ។ ហេតុនេះ ចៅក្រមនៃអង្គជំនុំជម្រះវិសាមញ្ញនឹងគួរតែពិចារណាថាកង្វះខាតឯករាជ្យភាពនិងភាពអនាគតិ (ដូច្នេះហើយ សិទ្ធិទទួលបាននូវការកាត់សេចក្តីដោយយុត្តិធម៌របស់ជនត្រូវចោទ ត្រូវបានកាត់សេចក្តីដោយចៅក្រមនោះ) ប្រសិនបើមានតែនៅក្នុងករណីណាមួយ (១) "មានភាពលម្អៀងដោយ ពិតប្រាកដ" (ការវិនិច្ឆ័យជាអត្តនោម័ត)

---

[91] រឿងក្តីសហរដ្ឋអាមេរិក *Shaw តទល់* Commonwealth of Pennsylvania (580 A.2d 1379 (Pa. Super. Ct, 1990) និង*រឿងក្តី* People *តទល់* Titone (600 N.E.2d 1160, 1166 (Ill. 1992)) បង្កើតតម្រូវការពីរដែលត្រូវតែស្វែងរកមុនពេលដែលចៅក្រមត្រូវបានកាត់សេចក្តីថាលំអៀង ឬខ្វះឯករាជ្យភាព/លំអៀង នឹងត្រូវបានបង្កើតឡើងគឺថា៖ (១) ភាពជាប់ទាក់ទងរវាងសកម្មភាពក្នុងមន្ទិល [គឺថា អំពើពុករលួយ] និងការប្រព្រឹត្តរបស់ចៅក្រមនៅសវនាការ និង(២) ភាពលំអៀងដែលបណ្តាលមកពីការប្រព្រឹត្តក្រៅតុលាការរបស់ចៅក្រម៖ *រឿងក្តី* Titone ទំព័រ1166។

[92] ឧទាហរណ៍ សូមមើល ក្រមនីតិវិធីព្រហ្មទណ្ឌរបស់អាល្លឺម៉ង់ (Strafprozeßordnung), មាត្រា ២២-២៤; ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មាត្រា៦៦៨; ក្រមនីតិវិធីព្រហ្មទណ្ឌអ៊ីតាលី មាត្រា៣៤-៣៦; ក្រមនីតិវិធីព្រហ្មទណ្ឌហូឡង់ (Wetboek van Strafvordering) មាត្រា ៥១២-៥១៩។ វាគួរត្រូវបានកត់សម្គាល់ថា តាមច្បាប់ជាទូទៅ ប្រទេសទាំងនេះក៏ចាត់ទុកថាភាពលំអៀងជាក់លាក់ជាមូលដ្ឋាននៃការដកចៅក្រមចេញ។

[93] *រឿងក្តី* *Findlay តទល់ United Kingdom* [១៩៩៧] ព្រឹត្តិប័ត្រពីររបស់ Civil តាមច្បាប់ជាទូទៅ ប្រទេសទាំងនេះក៏ចាត់ទុកថាភាពលំអៀងជាក់លាក់ជាមូលដ្ឋាននៃការដកចៅក្រមចេញ។ Liberties 13.5, 24 EHRR221, កថាខណ្ឌ៣ [*បន្ទាប់ពីនេះ* រឿងក្តី Findlay]។

ឬ(២) មាន "ការបង្កើតឲ្យមានភាពលម្អៀងដែលមិនអាចទទួលយកបាន" (ការវិនិច្ឆ័យជាសត្យានុម័ត)[94]។

៤៦. យុត្តិសាស្ត្រដែលយោងនៅក្នុងរឿងក្តី Furundzija ត្រូវបានយកអនុវត្តជាទូទៅដោយតុលាការអន្តរជាតិ និងមានលក្ខណៈស្របគ្នាទៅនឹងការវិនិច្ឆ័យដើម្បីរកឲ្យឃើញពីភាពលម្អៀងរបស់ចៅក្រមដែលធ្វើឡើងដោយអង្គបុរេជំនុំជម្រះ[95]។ ពាក់ព័ន្ធនឹងបណ្តឹងជិតចិត្តរបស់ចៅក្រម លក្ខណៈវិនិច្ឆ័យនេះមានចែងនៅក្នុងវិធាន ៣៤(២) នៃវិធានផ្ទៃក្នុងដែលនិយាយដល់ភាពអនាគតិពិតប្រាកដផង និងការបង្កើតឲ្យមានភាពលម្អៀង[96]។ អង្គបុរេជំនុំជម្រះបានអនុវត្តតាមយុត្តិសាស្ត្រនៃរឿងក្តី នៅពេលធ្វើសេចក្តីសម្រេចលើបណ្តឹងជិតចិត្តចំពោះចៅក្រម ន័យ ថុល ដែលធ្វើឡើងដោយជនត្រូវចោទ នួន ជា ដោយសារតែភាពពាក់ព័ន្ធនឹងនយោបាយរបស់ចៅក្រមរូបនេះ ព្រមទាំងសមាជិកភាពនៃកងយោធពលខេមរភូមិន្ទរបស់គាត់ផងដែរ។ នៅក្នុងការអនុវត្តតាមយុត្តិសាស្ត្រនោះ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ឃើញថា ការសន្មតពីភាពអនាគតិបានអនុវត្តចំពោះចៅក្រមរបស់តុលាការនេះ ដោយអនុលោមតាមមាត្រា ៣.៣ នៃកិច្ចព្រមព្រៀង[97]។ ការសន្មតនេះកើតចេញមកពីការស្បថចូលធ្វើការរបស់ចៅក្រមទាំងនោះ និងសមត្ថភាពដែលកំណត់លក្ខខណ្ឌសម្រាប់ការតែងតាំងចៅក្រមទាំងនោះ[98]។ អ្នកដាក់ពាក្យបណ្តឹងស្វែងរកការផ្លាស់ប្តូរចៅក្រមនោះបង្ហាញឡើងនូវបន្ទុកធ្ងន់[99] និងត្រូវលើកនូវភស្តុតាងឲ្យបានគ្រប់គ្រាន់

---

[94] សេចក្តីសម្រេច Furundzija, កថាខណ្ឌ ១៨៩-១៩០; *រឿងក្តីរដ្ឋអាជ្ញា តទល់ Brdamin & Talic*, សេចក្តីសម្រេចលើពាក្យសុំដោយ Momir Talic សម្រាប់ការបញ្ឈប់ និងការដកខ្លួនរបស់ចៅក្រម, អង្គជំនុំជម្រះII នៃ ICTY, ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០០, កថាខណ្ឌ១៣, ជើងទំព័រ៣៦។

[95] សេចក្តីសម្រេចរបស់ចៅក្រម ន័យ ថុល, កថាខណ្ឌ២០។

[96] សេចក្តីសម្រេចរបស់ចៅក្រម ន័យ ថុល, កថាខណ្ឌ១២។

[97] សេចក្តីសម្រេចរបស់ចៅក្រម ន័យ ថុល, កថាខណ្ឌ១៥។ សូមមើលផងដែរ *រឿងក្តីរដ្ឋអាជ្ញា តទល់ Dario Kordic និងអ្នកផ្សេងទៀត*, សំណុំរឿងលេខ IT-95-14/2-PT, សេចក្តីសម្រេចរបស់ the Bureau, ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ១៩៩៨, ទំព័រ២។ *រឿងក្តីរដ្ឋអាជ្ញា តទល់ Akayesu*, សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលឧទ្ធរណ៍, សំណុំរឿងលេខ ITCR-96-4, ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០១, កថាខណ្ឌ៩០ [*បន្ទាប់ពីនេះ* សេចក្តីសម្រេច Akayesu]។

[98] សេចក្តីសម្រេចរបស់ចៅក្រម ន័យ ថុល, កថាខណ្ឌ១៦។

[99] ដូចជើងទំព័រខាងលើ, កថាខណ្ឌ១៥។

00334715



ដើម្បីបញ្ជាក់ថា ចៅក្រមដែលមានបញ្ហាអាចត្រូវបានគេដឹងថាមានភាពលម្អៀងពិតប្រាកដមែន[100]។ នៅពេលដែលគ្មានភស្តុតាងផ្ទុយទេនោះ វាត្រូវបានសន្មតថា ចៅក្រម "អាចលាងជម្រះខ្លួនឱ្យរួចផុតពីជំនឿ ឬបុព្វហេតុដែលមិនមានភាពពាក់ព័ន្ធណាមួយនោះ"[101]។

៤៧. ដោយអនុវត្តតាមរឿងក្ដី Furundzija អង្គបុរេជំនុំជម្រះបានលើកឡើងថា មានការកើតឡើងនូវភាពលម្អៀង ក្នុងករណីៈ

i. ចៅក្រមគឺជាភាគីនៃរឿងក្ដី ឬមានផលប្រយោជន៍ជាកម្មសិទ្ធិ ឬហិរញ្ញវត្ថុ បានមកពីលទ្ធផលនៃរឿងក្ដី ឬក៏ ប្រសិនបើសេចក្ដីសម្រេចរបស់ចៅក្រមរូបនោះនឹងនាំឱ្យកើតមាននូវមូលហេតុដែលខ្លួនគាត់មានការពាក់ព័ន្ធ រួមគ្នាជាមួយនឹងភាគីណាមួយក្នុងចំណោមភាគីទាំងឡាយ។ ស្របតាមកាលៈទេសៈទាំងនេះ បណ្ដឹងជំទាស់ចៅក្រមដោយសាររឿងក្ដីគឺកើតមានជាស្វ័យប្រវត្តិ។ ឬក៏

ii. កាលៈទេសៈទាំងនេះនឹងនាំឱ្យអ្នកសង្កេតការណ៍ណាម្នាក់យល់ឃើញថាមានភាពលម្អៀងតាមរយៈព័ត៌មានដ៏ត្រឹមត្រូវ[102]។

៤៨. នៅក្នុងបរិបទនេះ អ្នកសង្កេតការណ៍ដ៏សមស្របគឺជាអ្នកដែលត្រូវបានផ្ដល់ព័ត៌មានពីការយល់ដឹងនូវរាល់កាលៈទេសៈទាំងអស់ដែលពាក់ព័ន្ធ រួមទាំងប្រពៃណីនៃសុច្ចរិតភាព និងភាពអនាគតិផងដែរ ព្រមទាំងបានដឹងពីអង្គហេតុដែលថា ភាពអនាគតិគឺជាភារៈកិច្ចមួយក្នុងចំណោមភារកិច្ចទាំងឡាយដែលចៅក្រមបានស្បថដើម្បីបំពេញតាម[103]។ អ្វីដែល

---

[100] ដូចជើងទំព័រខាងលើ, កថាខណ្ឌ១៩។ សេចក្ដីសម្រេច *Akayesu,* កថាខណ្ឌ៨៨។ សេចក្ដីសម្រេច Furundzija កថាខណ្ឌ១៩៦។

[101] សេចក្ដីសម្រេច Furundzija កថាខណ្ឌ១៩៦។

[102] សេចក្ដីសម្រេចរបស់ចៅក្រម ន័យ ថុល, កថាខណ្ឌ២០។

[103] *រឿងក្ដី នួន ជា,* សេចក្ដីសម្រេចជាសាធារណៈស្ដីពីបណ្ដឹងជំទាស់ចៅក្រមជាបន្ទាន់របស់សហមេធាវីជនត្រូវចោទ នួន ជា ចំពោះលោកចៅក្រម ន័យ ថុល, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០១), ERN

ជាលក្ខខ័ណ្ឌតម្រូវនៃ "អ្នកសង្កេតការណ៍សមស្រប" នោះ គឺ "ការលើកសរសើរទាំងរបៀបដែលការគាបសង្កត់ផ្នែកស្ថាប័ន [អាចដំណើរការបាន][104]។

### *៥.៣.៥ បណ្តឹងសុំឲ្យមានការវិនិច្ឆ័យលើភាពលម្អៀងនៅក្នុងយុត្តាធិការអន្តរជាតិ*

៤៩. នៅក្នុងរឿងក្តី Furundzija តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី បានបដិសេធលើសំណើសុំដិតចិត្តចៅក្រម ដោយហេតុថាតុលាការកំពុងវិនិច្ឆ័យរឿងក្តីដែលអាច និងប្រាកដជាជម្រុញបន្ថែមនូវរបៀបវារៈច្បាប់ និងនយោបាយដែលចៅក្រមនោះបានជួយបង្កើតឡើង នៅពេលដែលគាត់គឺជាសមាជិកនៃគណៈកម្មការស្តីពីស្ថានភាពស្ត្រីនៃអង្គការសហប្រជាជាតិមួយរូប នៅមុនពេលមានការតែងតាំងចៅក្រមនោះទៅបំពេញការងារនៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីនោះ[105]។ នៅក្នុងរឿងក្តី Akayesu តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីបានបដិសេធចំពោះការតវ៉ារបស់មេធាវីការពារដែលថា ការគម្រាមកំហែងផ្នែកនយោបាយបានបំផ្លាញដល់ឯករាជ្យភាព និងភាពអនាគតិរបស់តុលាការ។ ជនត្រូវចោទបានពោលថា ការកត់សម្គាល់ជាសាធារណៈ និងជាឯកជនដែលធ្វើដោយចៅក្រមដែលរួមជាមួយនឹង "ការគម្រាមកំហែង និងការរៀបចំពិសេស" បានបង្ហាញឲ្យដឹងពីកង្វះភាពអនាគតិចំពោះរូបគាត់។ តុលាការបានកត់សម្គាល់ឃើញថា បន្ទុកដែលនាំឲ្យមានកង្វះភាពអនាគតិតាមរយៈ "ភស្តុតាងគ្រប់គ្រាន់ និងគួរឲ្យជឿជាក់" គឺជារបស់ជនត្រូវចោទ និងកត់សម្គាល់ឃើញថា "ការចោទប្រកាន់ដែលគ្មានការពន្យល់បន្ថែម" អំពីភាពលម្អៀងនិងការផ្តន្ទាទោសតាមការ

---

00160734-00160742, C11/29, ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៨, កថាខណ្ឌ២១ [*បន្ទាប់ពីនេះ* សេចក្តីសម្រេចរបស់ចៅក្រម ន័យ ធុល]។

104 *រឿងក្តីរដ្ឋអាជ្ញា តទល់ Norman*, សំណុំរឿងលេខ SCSL-2004-14-AR72(E), យោបល់ដាច់ដោយឡែករបស់ Geoffrey Robertson, កថាខណ្ឌ១៨ [*បន្ទាប់ពីនេះ* សេចក្តីសម្រេចរឿងក្តី Norman]។

105 *រឿងក្តីរដ្ឋអាជ្ញា តទល់ Norman*, សំណុំរឿងលេខ SCSL-2004-14-AR72(E), យោបល់ដាច់ដោយឡែករបស់ Geoffrey Robertson, កថាខណ្ឌ១៨ [*បន្ទាប់ពីនេះ* សេចក្តីសម្រេចរឿងក្តី Norman]។

ជ្រើសរើសនោះ មិនមានលក្ខណៈគ្រប់គ្រាន់បំពេញនូវបន្ទុកនោះបានទេ[106]។ ស្រដៀងគ្នានេះដែរ តុលាការយុត្តិធម៌អន្តរជាតិនៅក្នុងរឿងក្តី Wall Case បានបដិសេធលើសំណើសុំរបស់ប្រទេសអ៊ីស្រាអែលដែលសុំឱ្យបដិសេធមិនឱ្យចៅក្រម កាន់រឿងក្តីនោះទេ ដោយហេតុថា តួនាទីមុនរបស់ចៅក្រមរូបនោះដែលជាអ្នកការទូតមួយរូបនៅក្នុងជម្លោះ អ៊ីស្រាអែល និងប៉ាឡេស្ទីននោះ ព្រមទាំងដោយសារការយល់ឃើញដែលគូសបញ្ជាក់ដោយ ចៅក្រមនោះទៅលើបញ្ហានោះនៅក្នុងការសួរយកចម្លើយមួយ។ តុលាការបានលើកឡើង ថា ចំពោះអង្គហេតុទាំងនោះតុលាការមិនអាចយល់ថា ចៅក្រមរូបនោះមាន "ការពាក់ព័ន្ធ ក្នុងផ្នែកណាមួយនៃរឿងក្តីនេះពីមុនមក" នោះទេ ទោះជានៅក្នុងសមត្ថកិច្ចណាក៏ដោយ[107]។

៥០. នៅក្នុងរឿងក្តី Nzirorera ជនត្រូវចោទបានស្នើតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រ្វ៉ាន់ដាសុំឱ្យបញ្ឈប់មេធាវីរបស់គាត់ដោយបានលើកឡើងនូវរឿងមួយក្នុងចំណោមរឿងជាច្រើនថា មេធាវីរូបនោះបានបំពេញការងារដោយភាពមិនស្មោះត្រង់និងធ្វើឱ្យខូចប្រយោជន៍កូនក្តីរបស់ខ្លួននិងរបស់តុលាការ ដោយសារគាត់បានស្នើជំនួយការច្បាប់របស់គាត់ឱ្យកែប្រែតម្លៃឈ្នួលរបស់គាត់ ឱ្យដល់កម្រិតអតិបរមានៃការប្រាក់ចំណាយសម្រាប់មេធាវី[108]។ អង្គជំនុំជម្រះបានទទួលស្គាល់ថា រឿងនេះគឺជា "ការចោទប្រកាន់យ៉ាងធ្ងន់ធ្ងរដែលត្រូវធ្វើការស៊ើបអង្កេតដោយអាជ្ញាធរមានសមត្ថកិច្ច"។ ទោះបីជាយ៉ាងណាក៏ដោយ តុលាការបានលើកឡើងថា ការចោទប្រកាន់ពីភាពមិនស្មោះត្រង់ផ្នែកហិរញ្ញវត្ថុរបស់មេធាវីនោះ គឺជាបញ្ហារដ្ឋបាលដែលគ្របដណ្តប់ដោយអំណាចរបស់ក្រឡាបញ្ជី មិនមែន

---

[106] *រឿងក្តីរដ្ឋអាជ្ញា តទល់Akayesu,* សេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍, សំណុំរឿងលេខ ICTR-96-4, ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០១, កថាខណ្ឌ៩០។

[107] *ផលវិបាកផ្លូវច្បាប់នៃការសាងសង់កំផែងក្នុងទឹកដីគ្រប់គ្រងដោយប៉ាឡេស្ទីន,* ដីកាចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៤ (២០០៤) ICJ Rep3 ។

[108] *រឿងក្តីរដ្ឋអាជ្ញា តទល់ Joseph Nzirorera,* សំណុំរឿងលេខ ICTR-44-T, សេចក្តីសម្រេចលើសំណើរបស់ជនជាប់ចោទ សុំប្តូរមេធាវីចាត់តាំង, អង្គជំនុំជម្រះ II, ចុះថ្ងៃទី៣ ខែតុលា ឆ្នាំ២០០១, [*បន្ទាប់ពីនេះ* សេចក្តីសម្រេច Nziroera]។

តុលាការសាលាដំបូងនោះទេ[109]។ នៅក្នុងរឿងក្តី Norman មន្ត្រីយុត្តិធម៌ Robertson បានលើកឡើងថា ឯករាជ្យភាពតុលាការរបស់តុលាការពិសេសសម្រាប់សេរ៉ាឡេអូន មិនរងនូវការប៉ះពាល់ដោយសារការរៀបចំមូលនិធិនោះទេ ពីព្រោះមិនមាន "គ្រោះថ្នាក់ពិតប្រាកដ" ដែលការចាត់ចែង គឺជា ឬនឹងជាលទ្ធផលនៃការគាបសង្កត់លើចៅក្រមរបស់តុលាការឱ្យសម្រេចសេចក្តីលើរឿងក្តីតាមវិធីពិសេសណាមួយឡើយ[110]។ នៅក្នុងរឿងក្តីដោយឡែកមួយទៀត តុលាការពិសេសសម្រាប់សេរ៉ាឡេអូន បានដកសិទ្ធិចៅក្រមមិនឱ្យចូលរួមសវនាការរឿងក្តីនោះ ដោយសារគាត់បានសម្តែងនូវការយល់ឃើញនៅក្នុងសៀវភៅមួយដែលត្រូវបានបោះពុម្ពផ្សាយស្តីពីឧក្រិដ្ឋកម្មនានាដែលត្រូវបានប្រព្រឹត្តដោយភាគីមួយនៃរឿងក្តីនោះ[111]។

### *៥.៣.៦ ឯករាជ្យភាពនិងភាពអនាគតិរបស់មន្ត្រីតុលាការ ដែលមិនមែនជាចៅក្រម*

៥១. ជាសំខាន់ ការសន្មតពីភាពអនាគតិសំដៅតែលើចៅក្រមនៃអង្គជំនុំជម្រះវិសាមញ្ញតែប៉ុណ្ណោះ[112]។ វាមិនមានការធានាអំពីភាពអនាគតិរបស់មន្ត្រីរដ្ឋបាលដែលមានតម្លៃស្មើគ្នានោះទេ ហើយក៏គ្មានដើមបណ្តឹងឧទ្ធរណ៍ណាអាចចង្អុលបង្ហាញពីច្បាប់ណាមួយដែលគាំទ្រដល់សំណើនោះដែរ។ ផ្ទុយទៅវិញ ស្របនឹងយុត្តិសាស្ត្រដែលបានពិភាក្សាខាងលើ និងដោយសារតែតុលាការនេះបានទទួលស្គាល់រួចមកហើយ ច្បាប់ដែលពាក់ព័ន្ធផ្តល់យោបល់

---

[109] អង្គជំនុំជម្រះបានសម្រេចដូច្នេះបន្ទាប់ពីបានពិចារណាលើមាត្រា១៦(១) នៃលក្ខន្តិកៈ ICTR និងសេចក្តីណែនាំស្តីពីការចាត់តាំងមេធាវីការពារក្តី ដែលរួមទាំងតួនាទីរបស់ក្រឡាបញ្ជីលើបញ្ហារដ្ឋបាល ទាក់ទងនឹងមេធាវីការពារក្តីដែលត្រូវបានចាត់តាំង៖ *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ២០។

[110] សេចក្តីសម្រេចរឿងក្តី Norman, កថាខណ្ឌ៣។

[111] *រឿងក្តីរដ្ឋអាជ្ញា តទល់ Sesay,* សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តីស្នើសុំការបញ្ឈប់ចៅក្រម Justice Robertson ពីសាលាឧទ្ធរណ៍, សំណុំរឿងលេខ SCSL-2004-15-AR15, ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៤។

[112] សេចក្តីសម្រេចរបស់ចៅក្រម ន័យ ធុល, កថាខណ្ឌ១៥-១៦។

ថាការធានាពីឯករាជ្យភាពនិងភាពអនាគតិនោះ"អនុវត្តតែចំពោះចៅក្រមតែប៉ុណ្ណោះ"[113]។ នោះគឺ មន្ត្រីតុលាការដែលទទួលខុសត្រូវចំពោះកិច្ចស៊ើបសួរ ការកាត់សេចក្តី ឬបណ្តឹងឧទ្ធរណ៍របស់ចុងចោទ។ សេចក្តីសម្រេចនេះបានសម្រេចជាស្ថាពរ បន្ទាប់ពីជនត្រូវចោទជ្រើសរើសមិនប្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចនោះ។

### *៥.៣.៧ ការប្រព្រឹត្តដែលមិនពាក់ព័ន្ធទៅនឹងការធ្វើសេចក្តីសម្រេចរបស់តុលាការមិនប៉ះពាល់ដល់សិទ្ធិនានាក្នុងការទទួលបាននូវការកាត់សេចក្តីដោយយុត្តិធម៌នោះទេ*

៥២. ទោះបីជាអសីលធម៌ឬខុសច្បាប់ក៏ដោយ ឥរិយាបថដែលមិនពាក់ព័ន្ធទៅនឹងការធ្វើសេចក្តីសម្រេចទេនោះ មិនប៉ះពាល់ដល់សិទ្ធិនានាក្នុងការទទួលបាននូវការកាត់សេចក្តីដោយយុត្តិធម៌នោះទេ។ ការប្រព្រឹត្តមិនសមរម្យអាចត្រូវបានគេសង្កេតឃើញនៅក្នុងយុត្តាធិការដែលត្រូវបានបង្កើតឡើងផ្សេងទៀតដែលនៅត្រង់ចំណុចការប្រព្រឹត្តបែបនោះមិនចាំបាច់ធ្វើឲ្យរឿងក្តីព្រហ្មទណ្ឌ ត្រូវបានបដិសេធចោលដោយសារតែការប្រព្រឹត្តនេះប៉ះពាល់ដល់សិទ្ធិនានាក្នុងការទទួលបាននូវការកាត់សេចក្តីដោយយុត្តិធម៌របស់ជនត្រូវចោទនោះឡើយ។ រហូតដល់ពេលបច្ចុប្បន្ននេះ ប្រធានតុលាការអង់គ្លេស the Lord Chancellor ក្នុងពេលដំណាលគ្នា គឺជាអ្នកនាំពាក្យរបស់សភាជាន់ខ្ពស់របស់ចក្រភពអង់គ្លេស និងជាសមាជិកផ្នែកប្រតិបត្តិ ដែលបានតំណាងឲ្យបញ្ហាទំនាស់ផលប្រយោជន៍នានា[114]។ នៅសហរដ្ឋអាមេរិក ការបោះឆ្នោតរបស់តុលាការត្រូវបានធ្វើឲ្យខូចខាតដោយសារការព្រួយបារម្ភថាវិភាគទានចំពោះយុទ្ធនាការបោះឆ្នោតរបស់ចៅក្រម នឹងជះឥទ្ធិពលលើការធ្វើសេចក្តីសម្រេចរបស់តុលាការដោយចៀសមិនរួចឡើយ។ ៦០%នៃចៅក្រមតុលាការសាលាឧទ្ធរណ៍ និង ៨០% នៃចៅក្រមសាលាដំបូងនៅកម្រិតរដ្ឋនៅក្នុងសហរដ្ឋអាមេរិកបានប្រឈមនឹងការបោះឆ្នោតដែលត្រូវបានប្រកួតប្រជែងគ្នា រីឯចៅក្រមត្រឹមតែ ១១%

---

[113] រឿងក្តី អៀង សារី, សំណើសុំផ្តល់ព័តមានទាក់ទងនឹងករណីទំនាស់ផលប្រយោជន៍ជាយថាហេតុ, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, ERN 00159515-00159516, ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៨, ទំព័រទី២។

[114] របាយការណ៍ស្តីពីអំពើពុករលួយពិភពលោក, ទំព័រxxiii។

ប៉ុណ្ណោះមិនបានប្រឈមនឹងការបោះឆ្នោតនោះទេ។ ជាពិសេសនៅក្នុងការបោះឆ្នោតដែលត្រូវបានប្រកួតប្រជែង និងជួនកាលនៅក្នុងការបោះឆ្នោតជ្រើសរើសចៅក្រមផងដែរ ចៅក្រមនានាបានលើកពីបញ្ហាមូលនិធិនៃយុទ្ធនាការបោះឆ្នោត[115]។ ដោយមានករណីលើកលែងតែមួយគត់នាពេលថ្មីៗនេះ[116] តុលាការកំពូលសហរដ្ឋអាមេរិកបានបដិសេធយ៉ាងម៉ឺងម៉ាត់ចំពោះ សំណើសុំពិនិត្យករណីដែលភាគីមួយក្នុងចំណោមភាគីទាំងឡាយគឺជាអ្នកផ្តល់វិភាគទាន ដល់យុទ្ធនាការបោះឆ្នោតដ៏សំខាន់ម្នាក់ជូនដល់ចៅក្រមដែលកាន់រឿងក្តីរបស់ពួកគេ[117]។

៥៣. តុលាការកំពូលសហរដ្ឋអាមេរិកបានទទួលស្គាល់ថា ជនត្រូវចោទមានសិទ្ធិទទួលបាននូវការកាត់សេចក្តីដោយយុត្តិធម៌ ប៉ុន្តែមិនមែនការកាត់សេចក្តីដោយសុក្រិត្យនោះទេ ពីព្រោះពុំមានការកាត់សេចក្តីណាដែលមានលក្ខណៈសុក្រិត្យនោះទេ[118]។ ជាការពិត អញ្បាកិត្យភាពដ៏ពិតប្រាកដអាចសម្រេចបានយ៉ាងពិបាក[119]។ សណ្តានចិត្តផ្នែកនយោបាយមិនបញ្ជាក់ពីកង្វះភាពអនាគតិនោះទេ[120]។ ដូចគ្នានេះដែរ នៅក្នុងករណីពុំមានភស្តុតាងផ្ទុយទេ

---

115 Roy A. Schotland, "ការបោះឆ្នោតតុលាការក្នុងសហរដ្ឋអាមេរិក៖ តើអំពើពុករលួយជាបញ្ហាមួយឬ?", *របាយការណ៍ស្តីពីអំពើពុករលួយពិភពលោក, ដូចជើងទំព័រខាងលើ,* ទំព័រ២៧។

116 *រឿងក្តី Caperton តទល់ A.T. Masey Coal Company*, លេខ 08-22, កោះហៅដោយ តុលាការកំពូលសហរដ្ឋ ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០០៩។ សេចក្តីសម្រេចរបស់តុលាការកំពូលមិនទាន់ចេញនៅឡើយ។ ត្រូវបានពិភាក្សាក្នុងអត្ថបទរបស់ Adam Liptak, "Justice Hear Arguments on Money-Court Nexus", កាសែត *The New York Times*, ចេញផ្សាយថ្ងៃទី៤ ខែមីនា ឆ្នាំ២០០៩។

117 Roy A. Schotland, "ការបោះឆ្នោតតុលាការក្នុងសហរដ្ឋអាមេរិក៖ តើអំពើពុករលួយជាបញ្ហាមួយឬ?", *របាយការណ៍ស្តីពីអំពើពុករលួយពិភពលោក, ដូចជើងទំព័រខាងលើ,* ទំព័រ២៧។

118 *រឿងក្តី United States តទល់ Hastings,* 461 U.S. 499, 508 (1983); *រឿងក្តី Delaware តទល់ Van Arsdale,* 475 U.S. 673, 681 (1986), ត្រូវបានយោងក្នុង DiBiagio, *យោងខាងលើ,* កថាខណ្ឌ 613, ជើងទំព័រ១៣០។

119 សេចក្តីសម្រេចរឿងក្តី Furundzija, កថាខណ្ឌ២០៣។ សូមមើលផងដែរ *រឿងក្តី Attoney General តទល់ Adolf Eichmann,* សំណុំរឿងលេខ 40/61 ក្នុងតុលាការក្នុងសាលាដំបូងរបស់ Jerusalem, សាលាដំបូងរបស់ Jerusalum, ពេលសវនាការបណ្តឹងឧទ្ធរណ៍ 02-03។ មាននៅ៖ http://www.nizkor.org/ftp.cgi/people/e/eichmann.adolf/transcripts/ftp.py?people/e/eichmann.adolf/transcripts//Appeal/Appeal-Session-02-03.

120 សេចក្តីសម្រេចរឿងក្តី Furundzija, កថាខណ្ឌ២០៣។

នោះ សញ្ជាតិ ឬសាសនារបស់ចៅក្រមមិនអាចយកមកធ្វើជាភស្តុតាងនៃភាពលម្អៀង ឬភាពអនាគតិនោះទេ[121]។ នៅក្នុងតុលាការណាក៏ដោយ ចៅក្រមត្រូវតែផ្តាច់ខ្លួនពីការរំជួលចិត្តទាំងឡាយ[122]។ នៅក្នុងរឿងក្តី Eichmann មេធាវីការពារបានតវ៉ាថា ចៅក្រមអ៊ីស្រាអែលដែលកាន់រឿងក្តីប្រឆាំងនឹងជនត្រូវចោទ Nazi ដែលជាប់ចោទពីឧក្រិដ្ឋកម្មសង្គ្រាម នឹងមិនអាចខំប្រឹងធ្វើរឿងក្តីដោយគ្មានភាពលម្អៀងនោះទេ។ ការភ័យខ្លាចត្រូវបានបង្ហាញថាមិនប្រឆាំងនឹងចៅក្រមណាមួយជាពិសេសនោះទេ ប៉ុន្តែប្រឆាំងនឹងចៅក្រមទាំងបីរូប ដោយហេតុថា ចៅក្រមទាំងនោះគឺជា "កូនប្រុសរបស់ប្រជាជនជ្វីហ្វ និងប្រជាពលរដ្ឋអ៊ីស្រាអែល"[123]។ ចៅក្រមបានឯកភាពថា ពួកគាត់មិនអព្យាក្រឹត្យពាក់ព័ន្ធនឹងបទឧក្រិដ្ឋនោះទេ ហើយពួកគាត់ក៏មិនត្រូវបានកំណត់លក្ខខណ្ឌឲ្យអព្យាក្រឹត្យនោះដែរ។ អ្វីដែលជាបញ្ហានោះគឺ ពួកគាត់មានយុត្តិធម៌ពាក់ព័ន្ធនឹងជនត្រូវចោទ[124]។

## ៥.៤ ទឡ្ហីករណ៍

### *៥.៤.១ សំណើសុំមិនស្ថិតនៅក្នុងយុត្តាធិការរបស់សហចៅក្រមស៊ើបអង្កេតនោះទេ*

៥៤. សំណើសុំមិនស្ថិតនៅក្នុងយុត្តាធិការរបស់សហចៅក្រមស៊ើបអង្កេតនោះទេ។ គ្មានចំណុចណាមួយនៅក្នុងកិច្ចព្រមព្រៀង[125] ច្បាប់អ.វ.ត.ក[126] ឬវិធានផ្ទៃក្នុងដែលផ្តល់អំណាចដល់សហចៅក្រមស៊ើបអង្កេតឲ្យទទួលយក និងបំពេញកិច្ចតាមសំណើសុំនោះឡើយ។

---

[121] *រឿងក្តី Attoney General តទល់ Adolf Eichmann,* សំណុំរឿងលេខ 40/61 (តុលាការក្នុងសាលាដំបូងរបស់ Jerusalem) ពេលសវនាការលេខ 6, 1 Iyar 5721 (ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៦១)។ សេចក្តីសម្រេចលេខ៣ [*បន្ទាប់ពីនេះ* សេចក្តីសម្រេចរឿងក្តី Eichmann]។ មាននៅ៖ http://www.nizkor.org/ftp.cgi/people/e/eichmann.adolf/transcripts/ftp.py?people/e/eichmann.adolf/transcripts/Session/Session-006-01 .

[122] *ដូចជើងទំព័រខាងលើ។*

[123] *ដូចជើងទំព័រខាងលើ។*

[124] *ដូចជើងទំព័រខាងលើ។*

[125] កិច្ចព្រមព្រៀង, កថាខណ្ឌ២៣។

[126] ច្បាប់ អ.វ.ត.ក, មាត្រា៤៧ (ថ្មី)។

00334722



៥៥. តុលាការនេះគឺជាស្ថាប័ននៃសន្ធិសញ្ញាអន្តរជាតិ (កិច្ចព្រមព្រៀង) និង ច្បាប់របស់រដ្ឋសភាកម្ពុជា (ច្បាប់អ.វ.ត.ក)។ តុលាការនេះត្រូវបានបង្កើតឡើងដោយមានយុត្តាធិការច្បាស់លាស់និងមានដែនកំណត់។ តាមស្មារតីនៃមាត្រា ២ នៃច្បាប់អ.វ.ត.ក តុលាការនេះត្រូវបានកំណត់ឱ្យមានការពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មជាក់លាក់ ដែលត្រូវបានប្រព្រឹត្តនៅក្នុងទីតាំងមួយជាក់លាក់ និងក្នុងរយៈពេលមួយជាក់លាក់។ វានៅក្នុងចំណុចនេះឯងដែលសហចៅក្រមស៊ើបអង្កេត ត្រូវពិចារណាអំពីលទ្ធភាពផ្លូវច្បាប់របស់ខ្លួនក្នុងការបំពេញកិច្ចតាមសំណើសុំស៊ើបអង្កេតនោះ។

៥៦. ទោះបីជាបំពេញបាននូវលក្ខខណ្ឌវិនិច្ឆ័យសម្រាប់“កិច្ចស៊ើបសួរ” ដូចដែលបានកំណត់អត្ថន័យដោយអង្គបុរេជំនុំជម្រះក៏ដោយ[127] សំណើសុំស៊ើបអង្កេតណាមួយដែលស្វែងរកឱ្យឃើញនូវការពិតអំពីបញ្ហាកម្មវត្ថុ ដែលមិនចូលទៅក្នុងអង្គហេតុដែលត្រូវបានកំណត់នៅក្នុងសេចក្តីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបន្ថែម ហើយដែលមិនពាក់ព័ន្ធទៅនឹងអំណាចរបស់តុលាការ ស្របតាមមាត្រា ២ នៃច្បាប់អ.វ.ត.ក ទេនោះ គឺស្ថិតនៅក្រៅអំណាចរបស់សហចៅក្រមស៊ើបអង្កេត។ ទោះបីជាសំណើសុំនេះ គឺជា “សំណើសុំឱ្យបំពេញកិច្ចដោយសហចៅក្រមស៊ើបអង្កេត... ដោយមានគោលបំណងប្រមូលពត៌មានដែលនាំឱ្យរកឃើញនូវការពិត”[128] ដោយហេតុនោះបានបំពេញនិយមន័យនៃ “កិច្ចស៊ើបសួរ” របស់តុលាការក៏ដោយ ពត៌មាន/កិច្ចស៊ើបសួរដែលត្រូវបានស្នើសុំមិនគ្របដណ្តប់ដោយអង្គហេតុណាមួយ ដែលត្រូវបានកំណត់នៅក្នុងសេចក្តីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបន្ថែមនោះទេ។ ផ្ទុយទៅវិញ សំណើសុំត្រូវមានការចង្អុល

[127] នោះគឺជាសំណើសុំ “បំពេញកិច្ចដោយសហចៅក្រមស៊ើបអង្កេតឬ តាមរយៈការផ្ទេរអំណាចឱ្យដោយអ្នកស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញ ឬមន្ត្រីនគរបាលយុត្តិធម៌ ដោយមានគោលបំណងប្រមូលនូវពត៌មានដែលនាំឱ្យរកឃើញនូវការពិត”។ *រឿងក្តី ខៀវ សំផន,* សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចស្តីពីសិទ្ធិ និង កាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ, ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៩, A190/I/20, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ១១), កថាខណ្ឌ២៣។

[128] សំណើ, កថាខណ្ឌ ២៣។

បង្ហាញថាមានការពាក់ព័ន្ធនឹងពត៌មាន "ដែលនាំឱ្យរកឃើញនូវការពិត*អំពីអង្គជំនុំជម្រះវិសាមញ្ញ*"[129]។

៥៧. អាស្រ័យហេតុនេះ សហចៅក្រមស៊ើបអង្កេតមិនមានសិទ្ធិអំណាចក៏ដូចជាមិនមានការទទួលខុសត្រូវចំពោះការស៊ើបអង្កេតការចោទប្រកាន់ពីអំពើពុករលួយ លុះត្រាតែការចោទប្រកាន់ទាំងនោះ បង្កើតបានជាផ្នែកនៃការស៊ើបអង្កេតជាសារធាតុលើអង្គហេតុដែលមាននៅក្នុងសេចក្តីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរឬសេចក្តីសន្និដ្ឋានបន្ថែម។ អាស្រ័យហេតុនេះ សហចៅក្រមស៊ើបអង្កេត ពុំមានអំណាចដើម្បីបង្ហាញពីការចោទប្រកាន់ពីអំពើពុករលួយរបស់អង្គជំនុំជម្រះវិសាមញ្ញនោះឡើយ។

### *៥.៤.២ នីតិវិធីប្តឹងជំទាស់ចៅក្រមមិនអាចយកមកអនុវត្តបានទេ*

៥៨. ដូចដែលបានលើកឡើងខាងលើ វិធាននានាមិនបានចែងពីការផ្តល់អំណាចដល់សហចៅក្រមស៊ើបអង្កេត ដើម្បីស៊ើបអង្កេតលើការចោទប្រកាន់ពីអំពើពុករលួយនៅក្នុងចំណោមបុគ្គលិករដ្ឋបាលនោះទេ លុះត្រាតែឥរិយាបថបែបនេះប៉ះពាល់ដល់ភាពយុត្តិធម៌ ឬនីត្យានុកូលភាពនៃកិច្ចដំណើរការនីតិវិធីនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត។ ទោះបីជាយ៉ាងណាក៏ដោយ វិធាននានាបានចែងយ៉ាងច្បាស់អំពីនីតិវិធីសម្រាប់ ការប្តឹងជំទាស់ចៅក្រមប្រសិនបើគាត់មានការពាក់ព័ន្ធនឹងសកម្មភាពណាមួយ ដែលធ្វើឱ្យខូចប្រយោជន៍ដល់លក្ខខ័ណ្ឌឯករាជ្យភាពនិងភាពអនាគតិ[130]។

៥៩. ទោះបីជាប្រើទម្រង់ជាសំណើសុំបំពេញកិច្ចស៊ើបសួរហើយមិនមែនជាពាក្យបណ្តឹងជំទាស់ចំពោះចៅក្រមក៏ដោយ សំណើសុំនេះមិនបានចង្អុលបង្ហាញពីអ្វីមួយនៅលើកំណត់ហេតុដើម្បីស្នើសុំថាចៅក្រមមួយរូប ឬច្រើនគួរតែប្តឹងជំទាស់។ ជាលទ្ធផល បណ្តឹងឧទ្ធរណ៍នានា មិនបានដាក់ជូនតុលាការនូវភស្តុតាងនៃភាពលម្អៀងពិតប្រាកដឬ ភាពលម្អៀងដែល

---

[129] *ដូចដើងទំព័រខាងលើ*, កថាខណ្ឌ IV(A) (គូសបញ្ជាក់បន្ថែម)។

[130] វិធាននានា, វិធាន៣៤។

គេយល់ឃើញណាមួយ ចំពោះចៅក្រមណាម្នាក់ប្រឆាំងនឹងម្ចាស់បណ្តឹងឧទ្ធរណ៍ណាមួយនោះទេ។ ទាំងសំណើសុំ ទាំងបណ្តឹងឧទ្ធរណ៍នានា មិនបានលើកឡើងពីផលប្រយោជន៍ផ្ទាល់ខ្លួន ឬហិរញ្ញវត្ថុរបស់ចៅក្រមនៅក្នុងលទ្ធផលនៃកិច្ចដំណើរការនីតិវិធីនោះទេ។ យោងតាមចំណុចនេះ សន្និតថាសំណើសុំគឺជាបណ្តឹងជិតចិត្តចំពោះចៅក្រម សំណើសុំត្រូវបានយល់ខុស ហេតុដូច្នេះ សំណើសុំត្រូវបានបដិសេធចោលយ៉ាងត្រឹមត្រូវ។

### *៥.៤.៣ ការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលតុលាការមិនបានកើតមានឡើយ*

៦០. វិធាន ៣៥ អនុញ្ញាតឲ្យមានការដាក់ទណ្ឌកម្ម ឬ "បញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ច" ចំពោះជនដែលជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលតុលាការ។ ហេតុដូច្នេះ ចំពោះការដាក់ទណ្ឌកម្មរបស់បទបញ្ញត្តិនេះចំពោះជនដែលៈ (១) ជននោះត្រូវតែជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលតុលាការ និង (២) ការជ្រៀតជ្រែកនេះត្រូវតែធ្វើឡើងដោយចេតនាពិតប្រាកដ។

៦១. វាមិនមានអ្វីមួយនៅលើកំណត់ហេតុដែលចង្អុលបង្ហាញថា អំពើពុករលួយដែលត្រូវបានចោទប្រកាន់នៅក្នុងតុលាការនេះបាននាំឲ្យមានៈ (១) មានការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលតុលាការ (២) អំពើបែបនេះត្រូវបានធ្វើឡើងដោយ "ចេតនាពិតប្រាកដ" ឬក៏ (៣) អំពើ ទាំងនេះមានតម្លៃស្មើនឹងការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលតុលាការ។ ដោយគ្មានភស្តុតាងចំពោះបញ្ហានេះ ពុំមានចំណុចមួយដែលស្នើសុំថា សហចៅក្រមស៊ើបអង្កេតគួរតែ ឬអាច បំពេញកិច្ច ស្របតាមវិធាន ៣៥ នោះទេ។

### *៥.៤.៤ សំណើសុំមិនស្ថិតនៅក្នុងយុត្តាធិការដែលមានរបស់តុលាការនោះទេ*

៦២. គោលបំណងនៃអំណាចតុលាការដែលមាននោះ គឺដើម្បីធានាថា តុលាការមានលទ្ធភាពដោះស្រាយបញ្ហានានាដែលចាំបាច់ សម្រាប់ដឹកនាំការងារដែលស្ថិតនៅក្នុងយុត្តាធិការរបស់ខ្លួន[131]។ ដូចដែលបានកត់សម្គាល់រួចហើយ អំណាចដែលត្រូវបានទទួលស្គាល់ដោយ

---

[131] សាលក្រមលើការចោទប្រកាន់ពីការមាក់ងាយចៅក្រមក្នុងរឿងក្តី Beqa Beqai, កថាខណ្ឌ១០។

យុត្តាធិការអន្តរជាតិនោះ ត្រូវបានចងក្រងជាវិធាននៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ។ ទោះបីជាយ៉ាងណាក៏ដោយ អំណាចដែលមានណាមួយរបស់តុលាការ ត្រូវបានរឹតត្បិតតែចំពោះអំពើដែលធ្វើដោយតុលាការនៅក្នុងយុត្តាធិការដែលមាន និងដែលត្រូវបានបង្កើតឡើងរបស់ខ្លួនប៉ុណ្ណោះ ដើម្បីធានាថា ការអនុវត្តយុត្តាធិការនោះមិនមាន លក្ខណៈជ្រុលហួសហេតុនោះទេ។ ការរឹតត្បិតនោះនឹងមិនធ្វើឱ្យមានអំពើផ្សេងពីនេះ ដែលស្ថិតនៅក្រៅយុត្តាធិការរបស់តុលាការ ក្លាយជាអំពើដែលស្ថិតនៅក្នុងយុត្តាធិការ របស់តុលាការនោះទេ[132]។ ដូចដែលបានលើកឡើងខាងលើ ICJ បានសម្រេចថាយុត្តាធិការរបស់ស្ថាប័នតុលាការអន្តរជាតិអាចធ្វើឱ្យតុលាការចាត់វិធានការ ដើម្បីធានាថា ការអនុវត្តយុត្តាធិការរបស់ខ្លួនទៅលើអង្គសេចក្តី មិនត្រូវជ្រុលហួសហេតុនោះទេ ប្រសិនបើនៅពេលធ្វើចំណាត់ការនោះ និងដើម្បីរៀបចំដំណោះ ស្រាយរាល់បញ្ហាជម្លោះទាំងអស់តាមលំដាប់លំដោយគឺដើម្បីធានាការអនុវត្តតាមច្បាប់របស់តុលាការចំពោះ "ការកំណត់ការអនុវត្តតួនាទីតុលាការដែលមាន"[133]។ ការបកស្រាយស្រដៀងគ្នាអំពីខ្លឹមសារនិងគោលបំណងនៃអំណាចនានាដែលមាន ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងយុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រ៉្វាន់ដា និងតុលាការពិសេសសម្រាប់ សេរ៉ាឡេអូន[134]។

---

[132] ជាទូទៅសូមមើល *Northern Cameroons,* ទំព័រ២៩, ត្រូវបានយោងក្នុង សាលក្រមលើការចោទប្រកាន់ពីការមាក់ងាយចៅក្រមក្នុងរឿងក្តី Beqa Beqai, កថាខណ្ឌ១១។

[133] *Northern Cameroons,* ទំព័រ២៩, ត្រូវបានយោងក្នុង រឿងក្តីនៃការចោទប្រកាន់ពីការមាក់ងាយក្នុងរឿងក្តី Beqa Beqaj, កថាខណ្ឌ១១ (គូសបញ្ជាក់បន្ថែម)។

[134] សាលាក្តីទាំងនោះបានរកឃើញថា បើទោះជាដំណើការនីតិវិធីព្រហ្មទណ្ឌត្រូវបានផ្តល់ឱ្យក្រោមយុត្តាធិការស្តីពីការមាក់ងាយរបស់ពួកគេយ៉ាងណាក៏ដោយ សាលាក្តីទាំងនោះក៏មានយុត្តិធិការផ្ទាល់ខ្លួនដែរ ដែលទាញមកពីមុខងារតុលាការរបស់ពួកគេ ដើម្បីធានាថា ការអនុវត្តន៍ *យុត្តាធិការរបស់ពួកគេ* មិនត្រូវបានរំខាន និងថាមុខងារតុលាការជាមូលដ្ឋានរបស់ពួកគេត្រូវបានការពារ។ សេចក្តីសម្រេចពីការមាក់ងាយតុលាការក្នុងរឿងក្តី Tadic, កថាខណ្ឌ១៣, យោងយុត្តិសាស្ត្ររបស់ ICJ និង ICTY។

៦៣. មានតែស្ថិតក្រោម "កាលៈទេសៈពិសេស" ប៉ុណ្ណោះដែលនៅក្នុងរឿងក្តី Ntabakuze និង Kabiligi[135] តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រ៉្វាន់ដា បានប្រើប្រាស់អំណាចដែលមានរបស់ខ្លួនដើម្បីធ្វើឱ្យរបាយការណ៍ដែលត្រូវបានប្រថាប់ត្រារបស់អង្គការសហប្រជាជាតិបានដល់ភាគីនានា ដែលផ្ទុយពីនេះតុលាការនេះមិនមានកាតព្វកិច្ចក្នុងការផ្សព្វផ្សាយរបាយការណ៍នោះទេ[136]។ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រ៉្វាន់ដាបានលើកឡើងយ៉ាងច្បាស់លាស់ថា អំពើដែលត្រូវបានធ្វើឡើង "គឺមិនមែនចាត់ទុកការកំណត់រឿងរ៉ាវពីមុនថាពាក់ព័ន្ធនឹងបញ្ហាទៅថ្ងៃក្រោយនោះទេ"[137]។ លើសពីនេះទៀត មិនដូចនៅក្នុងរឿងក្តីនេះទេ ភាពពាក់ព័ន្ធនៃរបាយការណ៍ដែលត្រូវបានប្រថាប់ត្រារបស់អង្គការសហប្រជាជាតិទៅនឹងយុត្តាធិការ ដែលជាបញ្ហាកម្មវត្ថុរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រ៉្វាន់ដាមិនត្រូវបានតវ៉ានោះទេ[138]។ ស្ថិតក្នុងកាលៈទេសៈទាំងនេះ គេមិនឃើញថាតុលាការមានអំពើដែលស្ថិតនៅក្រៅយុត្តាធិការតុលាការក្នុងការផ្សព្វផ្សាយរបាយការណ៍ស្របតាមទ្រឹស្តីនៃអំណាចដែលមាននោះទេ។

៦៤. នៅពេលដែលយុត្តាធិការដែលមានរបស់តុលាការនេះ ត្រូវបានកម្រិតចំពោះភារកិច្ចរបស់ខ្លួននៅក្នុងយុត្តាធិការដែលមាននោះគឺ ដើម្បីធានាថាកិច្ចដំណើរការនីតិវិធីមានភាពយុត្តិធម៌ សហចៅក្រមស៊ើបអង្កេតមិនអាចយល់ព្រមតាមសំណើសុំបានទេ - ក្នុងការធ្វើដូច្នេះ អំពើនោះនឹងនៅក្រៅអំណាចរបស់ខ្លួន។

---

[135] *រឿងក្តីរដ្ឋអាជ្ញា តទល់ Ntabakuze និង Kabiligi,* សំណុំរឿងលេខ ICTR-96-34-I, សេចក្តីសម្រេចលើពាក្យស្នើសុំបន្ថែមរបស់ Kabiligi សម្រាប់ការស៊ើបអង្កេត និងការបង្ហាញភស្តុតាង, ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០០០, [*បន្ទាប់ពីនេះ* សេចក្តីសម្រេចក្នុងរឿងក្តី Kabiligi] (យោងទៅលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ២៦)។

[136] ដោយសាសហព្រះរាជអាជ្ញាមិនមានរបាយការណ៍នោះ របាយការណ៍នោះមិនត្រូវបង្ហាញក្រោមវិធានរបស់ ICTR ទេ--*ដូចជើងទំព័រខាងលើ,* កថាខណ្ឌ៨-១០។

[137] សេចក្តីសម្រេចក្នុងរឿងក្តី Kabiligi, កថាខណ្ឌ១៧។

[138] មេធាវីដែលស្នើសុំរបាយការណ៍ បានផ្តល់ទឡ្ហីករណ៍ថាការវាយប្រហាប្រធានបទនៃរបាយការណ៍ (ការវាយប្រហាលើយន្តហោះរបស់ប្រធានាធិបតី Habyarimana) គឺជាធាតុសំខាន់មួយក្នុងការរៀបគម្រោង និងការប្រព្រឹត្តឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរ៉្វាន់ដា ក្នុងឆ្នាំ១៩៩៤។ ការកាត់សេចក្តីស្នើថា ក្រុមការពារក្តីមិនបានបង្ហាញថា របាយការណ៍នោះ គឺជា "វត្ថុតាង" ដែលត្រូវបង្ហាញក្រោមវិធាន៦៦(ខ) នៃ ICTR។

00334727



### *៥.៤.៥ ការធ្វើសេចក្តីសម្រេចរបស់តុលាការមិនត្រូវបានប៉ះពាល់ ដោយអំពើពុករលួយដែលត្រូវបានចោទប្រកាន់នោះទេ*

៦៥. ការរំលោភបំពានណាមួយលើសិទ្ធិទទួលបាននូវការកាត់សេចក្តីដោយយុត្តិធម៌ គឺជាបញ្ហាធ្ងន់ធ្ងរ។ ទោះបីជាយ៉ាងណាក៏ដោយ ដោយសារតែគ្មានការពាក់ព័ន្ធរវាងការប្រព្រឹត្តដែលចោទជាបញ្ហា និងការប៉ះពាល់ដល់សិទ្ធិទទួលបាននូវការកាត់សេចក្តីដោយយុត្តិធម៌ដែលត្រូវបានចោទប្រកាន់នោះ កិច្ចស៊ើបសួរណាក៏ដោយគឺ "មិនពិតនិងមានលក្ខណៈជាទ្រឹស្តី"[139]។ ទោះបីជាត្រូវបានបង្ហាញថាត្រឹមត្រូវក៏ដោយ ការចោទប្រកាន់ពីការបង់ប្រាក់ដោយមន្ត្រីរដ្ឋបាលដើម្បីទទួលបានឬរក្សាបាននូវការងារនោះ ក៏មិនប្រាកដថាធ្វើឲ្យមានសេចក្តីសន្និដ្ឋានអំពីភាពលម្អៀងរបស់តុលាការនោះដែរ។ ដើមបណ្តឹងឧទ្ធរណ៍មិនបានផ្តល់នូវភស្តុតាង រឿងនិទាន ឬផ្សេងពីនេះ បញ្ជាក់ពីអំពីភាពលម្អៀងពិតប្រាកដរបស់ចៅក្រមផ្នែកណាម្នាក់ប្រឆាំងនឹងចុងចោទនោះទេ។

៦៦. បណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ អៀង សារី បានលើកឡើងថា ភស្តុតាងនៃអំពើពុករលួយអាចប៉ះពាល់ដល់សេចក្តីសន្និដ្ឋានលើអង្គហេតុដែលបានធ្វើ ឬនឹងត្រូវធ្វើដោយ សហចៅក្រមស៊ើបអង្កេត "ហេតុនេះហើយ វាគឺជាភស្តុតាងដោះបន្ទុក"[140]។ ដូចដែលបានលើកឡើង វាមានការពាក់ព័ន្ធត្រឹមតែអង្គហេតុដែលមាននៅក្នុងសេចក្តីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬសេចក្តីសន្និដ្ឋានបន្ថែមប៉ុណ្ណោះដែលសហចៅក្រមស៊ើបអង្កេត ត្រូវបានតម្រូវឲ្យដឹកនាំកិច្ចស៊ើបសួររបស់ខ្លួន ដោយភាពអនាគតិនិង ដោយមិនខ្វល់ទៅនឹងបញ្ហាថាតើជាភស្តុតាងដាក់បន្ទុកឬភស្តុតាងដោះបន្ទុកនោះទេ[141]។

៦៧. ឧទាហរណ៍នានាដែលត្រូវបានលើកឡើងនៅក្នុងសំណើសុំ[142] និងបានសម្តែងនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ អៀង សារី[143] ស្តីពីផលប៉ះពាល់នៃអំពើពុករលួយដែល

---

[139] សេចក្តីសម្រេចក្នុងរឿងក្តី Norman, កថាខណ្ឌ១៨។

[140] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, ផ្នែក (ii) (ក), កថាខណ្ឌ ២១, ៣៩-៤០។

[141] វិធាន ៥៥(២), (៥)។

[142] សំណើ, កថាខណ្ឌ១៩។

នឹងអាចកើតឡើងចំពោះសេចក្តីសន្និដ្ឋានលើអង្គហេតុដែលធ្វើដោយសហចៅក្រមស៊ើបអង្កេតនោះ គឺជាការសន្និដ្ឋានសុទ្ធសាធ។ ឧទាហរណ៍ទាំងនោះខកខានមិនបានបង្ហាញសោះឡើយពីការពាក់ព័ន្ធគ្នារវាងការបង់ប្រាក់ដើម្បីទទួលបានឬរក្សាបាននូវការងារ និងតួនាទីស៊ើបអង្កេតរបស់ចៅក្រមស៊ើបអង្កេត។ ចម្លើយដែលធ្វើឡើងដោយជនត្រូវចោទ នួន ជា ដែលថាមាន "បញ្ហាដែលអាចកើតមានឡើងទាក់ទិននឹងការប្រមូលភស្តុតាង"[144] ថាមន្ត្រី បុគ្គលិកនានា "អាចមានចេតនាដូចៗគ្នាក្នុងការធ្វើតាមការណែនាំដែលមិនត្រឹមត្រូវ" ឬ "អាចគិតថាជាកាតព្វកិច្ចក្នុងការបំពេញតួនាទីផ្លូវការរបស់ខ្លួន យោងតាមការសង្ឃឹមទុករបស់ហិរញ្ញិករបស់ខ្លួន"[145] នោះក៏គ្រាន់តែជាគំនិតដែលគ្មានការយល់ដឹងច្បាស់លាស់តែប៉ុណ្ណោះ។

៦៨. ពុំមានសំណើសុំ និងពុំមានបណ្តឹងឧទ្ធរណ៍ណាមួយ លើកឡើងពីផលប្រយោជន៍ផ្ទាល់ខ្លួន ឬហិរញ្ញវត្ថុដែលជាលទ្ធផលនៃ កិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញនោះទេ ឬក៏ពុំមានមធ្យោបាយផ្សេងទៀតដែលរឿងក្តីរបស់តុលាការ និងសិទ្ធិទទួលបានការកាត់សេចក្តីដោយយុត្តិធម៌របស់ចុងចោទ បានរងការប៉ះពាល់មិនល្អពីការប្រព្រឹត្តអំពើពុករលួយដែលត្រូវបានចោទប្រកាន់នោះដែរ។ ពុំមានប្រភពពត៌មានជាសាធារណៈណា មួយបានផ្តល់ជាភស្តុតាងនៃភាពលម្អៀងនៅក្នុងសំណុំរឿងណាមួយឡើយ។ ដើមបណ្តឹងឧទ្ធរណ៍មិនអាចលើកយកចំណុចសំខាន់នៃការសម្រេចរបស់តុលាការ ដែលគាំទ្រដល់ការអះអាងពីភាពលម្អៀងរបស់តុលាការនោះឡើយ។ ពុំមានពត៌មានណាមួយត្រូវបានរៀបចំដើម្បីបង្ហាញពីមូលហេតុនៃផ្នែកណាមួយដើម្បីឱ្យ "យល់ព្រម" ធ្វើការផ្តន្ទាទោស ឬមិនអញ្ចឹងទេ បង្ហាញពីមូលហេតុនៃការជ្រៀតជ្រែកដល់កិច្ចការរដ្ឋបាលដ៏ត្រឹមត្រូវនៅតុលាការនេះឡើយ។

---

[143] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ៣៩។

[144] បណ្តឹងឧទ្ធរណ៍របស់ នួន ជា, កថាខណ្ឌ១៦ (គូសបញ្ជាក់បន្ថែម)។

[145] សំណើ, កថាខណ្ឌ១៨ (គូសបញ្ជាក់បន្ថែម)។

00334729



៦៩. អាស្រ័យហេតុនេះ ភាពអាចជឿទុកចិត្តបានលើការកាត់សេចក្តីរបស់ អ.វ.ត.ក មិនបាន បង្ហាញឱ្យឃើញថាអាចនឹងត្រូវបានសម្រុះសម្រួលនោះទេ និងចំពោះអ្នកសង្កេតការណ៍ មិនលំអៀងដែលបានដឹងគ្រប់កាលៈទេសៈពាក់ព័ន្ធទាំងអស់ ក៏ហាក់ដូចជាមិនអាចសម្រុះ សម្រួលបានដែរ។

៧០. សហព្រះរាជអាជ្ញាកត់សម្គាល់ឃើញថា កាតព្វកិច្ចរបស់តុលាការក្នុងការផ្តល់ការកាត់ សេចក្តីដោយយុត្តិធម៌ជូនដល់អ្នកទាំងឡាយណា ដែលត្រូវបានយកមកកាត់ទោសនៅ ចំពោះមុខតុលាការនោះ គឺកំពុងតែបន្តទៅមុខ។ ទោះបីជាមានការខ្វះខាតនូវភាពទាក់ទង គ្នារវាងការបង់ប្រាក់និងការធ្វើសេចក្តីសម្រេចរបស់តុលាការក៏ដោយ ពត៌មានណាក៏ដោយ ដែលនឹងនាំយកមកឱ្យតុលាការធ្វើការពិចារណាជាបន្តបន្ទាប់នោះ គួរត្រូវបាន ពិចារណា យ៉ាងល្អិតល្អន់ និងត្រូវបានវាយតម្លៃនៅក្នុងបរិបទនៃការការពារសិទ្ធិក្នុងការ ទទួលបាននូវ ការកាត់សេចក្តីដោយយុត្តិធម៌របស់ជនត្រូវចោទ។

### *៥.៤.៦ វិធាននានាមិនអនុញ្ញាតតាមសំណើសុំពត៌មានដែលមិនទាន់មានមូលដ្ឋានជាពិតនោះទេ*

៧១. វិធាននានា ក៏ដូចជាការអនុវត្តរបស់កម្ពុជានិងអន្តរជាតិផងដែរ មិនអនុញ្ញាតតាមសំណើ សុំពត៌មានគ្រប់បែបយ៉ាងដែលមិនទាន់មានមូលដ្ឋានពិត ពាក់ព័ន្ធនឹងចៅក្រមព្រមទាំង អ្នកស៊ើបអង្កេតផងដែរ[146]។ ដោយមានការលើកលែងចំពោះសំណើសុំរបាយការណ៍ OIOS នោះ[147] សំណើសុំបានធ្វើឡើងដោយមានលក្ខណៈហួសហេតុ និងមានន័យមិន ច្បាស់លាស់ដោយមិនបានបង្ហាញនូវភស្តុតាងជាក់លាក់ណាមួយ ដែលអាចគាំទ្រដល់ការ កើតមានឡើង ឬការយល់ឃើញណាមួយអំពីភាពលម្អៀងចៅក្រមផ្នែកណាមួយរបស់ តុលាការនេះទេ[148]។

---

[146] *រឿងក្តី នួន ជា,* សំណើសុំបង្ហាញប្រវត្តិរូបចៅក្រមអង្គបុរេជំនុំជម្រះ, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, ឯកសារ C11/13, ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៧។

[147] សំណើ, កថាខណ្ឌ២២។

[148] ឧទាហរណ៍, សំណើ, កថាខណ្ឌ២២(គ), ស្នើសុំ "ព័ត៌មានទាំងឡាយលើកឡើងពីអំពើពុករលួយជាស្ថាប័ន ដែលមាន ប្រព័ន្ធរៀបចំចាត់ចែងជាមុននៅ អ.វ.ត.ក"។

៧២. ដើមបណ្តឹងឧទ្ធរណ៍ មិនមានសិទ្ធិទទួលបាននូវការបង្គាប់ឱ្យបង្ហាញឯកសារនិងពត៌មានដោយងាយស្រួលនោះទេ ពីព្រោះដើមបណ្តឹងឧទ្ធរណ៍បាននិយាយថា ឯកសារទាំងនោះ "អាច" បង្ហាញថាសិទ្ធិក្នុងការទទួលបាននូវការកាត់សេចក្តីដោយយុត្តិធម៌បានរងនូវផលប៉ះពាល់មិនល្អ។ ដើមបណ្តឹងឧទ្ធរណ៍មិនមានសិទ្ធិក្នុងការជីកកកាយរុករកពត៌មាន- ក្នុងន័យថា ដើមបណ្តឹងឧទ្ធរណ៍មានបំណងពិនិត្យឯកសារដែលត្រូវបានស្នើសុំដើម្បីរកមើលថាតើពួកគេបានលើកឡើងនូវទឡ្ហីករណ៍ណាមួយដែរឬទេ[149]។ សំណើសុំបំពេញកិច្ចស៊ើបសួរមិនដូចគ្នានឹងការទទួលបានការស៊ើបសួរ ប្រឆាំងនឹងភាគីម្ខាងទៀតនោះទេ[150]។ មុនពេលទទួលបាននូវការបង្គាប់ឱ្យពិនិត្យឯកសារនៅពេលដែលសិទ្ធិក្នុងការ ពិនិត្យនេះមិនត្រូវបានយល់ព្រមនោះ ភាគីស្នើសុំត្រូវបង្ហាញឱ្យបានច្បាស់លាស់ និងប្រាកដប្រជាអំពីគោលបំណងពាក់ព័ន្ធជាធម្មានុរូប អំពីការពិនិត្យណាមួយ ដែលត្រូវបានស្នើសុំ[151]។

---

[149] ពាក្យ "fishing expedition" ត្រូវបានឱ្យនិយមន័យថា នៅពេលដែលភាគីមិនមានភស្តុតាងថាមានត្រីប្រភេទណាមួយមាននៅក្នុងអាង ប៉ុន្តែចង់កៀរអាងនោះដើម្បីចង់ដឹងថាមានត្រីប្រភេទនោះដែរឬអត់៖ *រឿងក្តី Associated Dominions Assurance Society Pty Ltd តទល់ John Fairfax & Sons Pty Ltd* (1952) 72 WN (NSW) 250 នៅទំព័រ២៥៤។ សូមមើលផងដែរ *រឿងក្តី Hennessy តទល់ Wright* (1888) 24 QBD 445 នៅទំព័រ៤៤៨។ ពាក្យនោះត្រូវបានទទួលស្គាល់ដោយសាលាឧទ្ធរណ៍៖ *រឿងក្តី Air Canada តទល់ Secretary of State for Trade* [1983] 2 AC 394 (per Lord Wilberforce); *រឿងក្តី Alister តទល់ The Queen* (1984) 154 CLR 404 នៅទំព័រ៤១៤ (per Gibbs CJ និង សូមមើលផងដែរ Brennan J ទំព័រ ៤៥៥-៤៥៦)។

[150] *រឿងក្តី Burchard តទល់ Macfarlane* [1891] 2 QB 241 ទំព័រ២៤៧; *រឿងក្តី Commissioner for Railways តទល់ Small* (1938) 38 SR(NSW) 564 ទំព័រ៥៧៣-៥៧៤។ ប្រៀបធៀបផងដែរ *រឿងក្តី Bracy តទល់ Gramley, 520 U.S. (1997)* [*បន្ទាប់ពីនេះ* សេចក្តីសម្រេចក្នុងរឿងក្តី Bracy], ត្រូវបានយោងដោយ បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កថាខណ្ឌ២៨, ដែលទាក់ទងនឹងសំណើសុំស៊ើបអង្កេត។ តុលាការកំពូលសហរដ្ឋបានទទួលសំណើរបស់អ្នកស្នើសុំម្នាក់គឺ Bracy សុំឱ្យបង្ហាញវត្ថុតាងទាក់ទងនឹងអំពើពុករលួយតុលាការ។ "អំពើពុករលួយដែលជាប់ទាក់ទងមួយផ្នែក" តែឯងមិនគ្រប់គ្រាន់ដើម្បីអនុញ្ញាតឱ្យមានកិច្ចស៊ើបអង្កេតនោះទេ។ សេចក្តីសម្រេចរបស់តុលាការកំពូលដែលផ្តល់ឱ្យស៊ើបរកឱ្យឃើញ ក៏សំអាងលើការរកឃើញមួយដែលក្រុមមេធាវីជំនុំជម្រះរបស់ Bracy អាចត្រូវបាន តែងតាំងដោយរៀបចំទុកជាមុនដើម្បីបន្តការអនុវត្តន៍អំពើពុករលួយ។

[151] ពាក្យ "legitimate forensic purpose" ត្រូវបានទទួលស្គាល់យ៉ាងច្បាស់ក្នុងច្បាប់ទាក់ទងនឹងដីកា (ឬដីកាកោះហៅ)៖ ឧទាហរណ៍ សូមមើល *រឿងក្តី Burnah Oil Co Ltd តទល់ Bank of England* [1980] AC 1090 ទំព័រ 1113-1114 និង *រឿងក្តី Attorney General តទល់ Stuart* (1994) 34 NSWLR 667 ទំព័រ 681។

គួរតែត្រូវបានបង្ហាញថា វាហាក់ដូចជា ឬក៏យ៉ាងហោចណាស់ "តាមការប៉ាន់ស្មាន"[152] ថា ឯកសារដែលនាំយកមកនឹងជួយជាភស្តុតាងលើរឿងក្ដីរបស់ភាគីស្នើសុំ[153]។ សំណើសុំឱ្យមានការស៊ើបសួរដែលត្រូវបានដាក់ដោយគ្រាន់តែសង្ឃឹមថា ពត៌មានដែលត្រូវបានស្នើសុំអាចបញ្ចេញនូវភស្តុតាង ដែលអាចគាំទ្រដល់ការប៉ះពាល់លើសិទ្ធិទទួលបានការកាត់សេចក្ដីដោយយុត្តិធម៌ គឺពិតជាសមនឹងត្រូវបានបដិសេធចោល។

### *៥.៤.៧ តុលាការនេះមិនមែនជាវេទិកាដើម្បីស៊ើបអង្កេតលើអំពើពុករលួយដែលស្ថិតនៅក្រៅរឿងក្ដីតុលាការនោះទេ*

៧៣. មន្ត្រីរដ្ឋបាលនៃតុលាការនេះ គឺជានិយោជិករបស់រាជរដ្ឋាភិបាល ឬអង្គការសហប្រជាជាតិ ដូចនេះហើយ មន្ត្រីទាំងនោះត្រូវបានគ្រប់គ្រងដោយច្បាប់របស់ស្ថាប័នទាំងនោះ[154]។ ទោះបីជាមន្ត្រីរដ្ឋបាលទាំងនោះត្រូវបានចងកាតព្វកិច្ចឱ្យបំពេញភារៈកិច្ចរបស់ ខ្លួនដោយគ្មានការជ្រៀតជ្រែកពីខាងក្រៅណាមួយក៏ដោយ[155] ពួកគេគឺជាអ្នកនៅក្រោមការ គ្រប់គ្រងតាមបទវិន័យ (រួមទាំងអំណាចនៃការបណ្ដេញចេញ) របស់អាជ្ញាធរមានសមត្ថកិច្ចកម្ពុជា និងអង្គការសហប្រជាជាតិ[156]។

៧៤. យោងតាមចំណុចនេះ កិច្ចដំណើរការបញ្ឈប់ឬដាក់ទណ្ឌកម្មលើមន្ត្រីបែបនេះគឺស្ថិតនៅក្រៅវិស័យតុលាការនេះ លើកលែងតែបទបញ្ញត្តិនៃវិធាន ៣៥ នៃវិធានផ្ទៃក្នុង (ដែលពាក់ព័ន្ធនឹងការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលតុលាការ) ត្រូវបានប្រើប្រាស់។ វាមិនមានភាព

---

[152] រឿងខ្លះគឺស្ថិត "នៅលើការប៉ាន់ស្មាន" ហើយប្រសិនបើវាមានឱកាសល្អ វានឹងកើតឡើង។

[153] *រឿងក្ដី Alister តទល់ The Queen* (1984) 154 CLR 404 ទំព័រ414។ ការសាកល្បងនេះត្រូវបានទទួលយកដោយតុលាការ New South Wales of Criminal Appeal ដោយបំពេញគ្រប់តម្រូវការ that there be legitimate forensic purpose for having access to the documents: *រឿងក្ដី Regina តទល់ Saleam* (1989) 16 NSWLR 14 ទំព័រ១៧-១៨ ។ ត្រូវបានយោងក្នុង Delalic, កថាខណ្ឌ៤, ជើងទំព័រ៥។

[154] វិធាន, វិធាន៦។

[155] *ដូចជើងទំព័រខាងលើ*, វិធាន៦(១)។

[156] *ដូចជើងទំព័រខាងលើ*, វិធាន៦(៤)។

សមស្របហើយក៏មិនស្របច្បាប់ដែរ នៅពេលដែលស្ថាប័នមួយ(ឬច្រើន)ផ្សេងទៀត គឺជាវេទិកាសមស្របដើម្បីកំណត់ថាតើមានការប្រព្រឹត្តខុសច្បាប់ និងមានការសន្និដ្ឋាន ថាតើការរំលោភបំពានត្រូវទទួលការផ្តន្ទាទោសឬទេ ហើយប្រសិនបើទទួលការផ្តន្ទាទោស តើទោសនោះមានទំហំប៉ុណ្ណានោះ។ សហព្រះរាជអាជ្ញាបានលើកឡើងម្តងទៀតថា អំពើពុករលួយនៅក្នុងតុលាការនេះ គឺពិតជាបញ្ហាធ្ងន់ធ្ងរខ្លាំងណាស់ដែលមិនអាចអត់ឱនបាន។ ឥរិយាបថពុករលួយណាមួយឬការប្រព្រឹត្តខុសច្បាប់ណាមួយត្រូវតែបញ្ចប់ ក្រោយពេលដែលជនល្មើសដែលបានចោទប្រកាន់ ត្រូវបានផ្តល់នូវសវនាការមួយដោយអាជ្ញាធរមានសមត្ថកិច្ច។ ទោះបីជាយ៉ាងណា នៅដំណាក់កាលនេះ ស្ថាប័ននានារបស់តុលាការនេះមិនមែនជាស្ថាប័នមានសមត្ថកិច្ចដើម្បីធ្វើការស៊ើបសួរលើឥរិយាបថបែបនេះទេ។

### *៥.៤.៨ ដំណោះស្រាយខាងក្រៅ មិនទាន់អស់លទ្ធភាពទេ*

៧៥. សហមេធាវីការពារជនត្រូវចោទ នួន ជា បានកត់ត្រាលម្អិតពីវិធីដែលត្រូវប្រកាន់យកនៅក្នុងសំណើសុំ ទៅតាមតួនាទីរបស់ខ្លួនផ្ទាល់និងក្នុងនាមកូនក្តីរបស់ខ្លួន ដើម្បីទទួលបាននូវពត៌មានដែលបានស្នើសុំ - ជាពិសេសគឺរបាយការណ៍ OIOS [157]។ មធ្យោបាយ ពីផ្នែកខាងក្រៅដើម្បីទទួល បានពត៌មានដែលត្រូវការទាំងនេះមិនត្រូវបានធ្វើឱ្យអស់លទ្ធភាពនៅឡើយទេ។ ការសាកសួរពីអំពើពុករលួយរបស់តុលាការក្រុងភ្នំពេញ ដែលផ្តើមគំនិតដោយសហមេធាវី អន្តរជាតិការពារជនត្រូវចោទ នួន ជា កាលពីខែមករា ឆ្នាំ២០០៩[158] នោះតាមសហ ព្រះរាជអាជ្ញាដឹង គឺបច្ចុប្បន្នទនេះកំពុងជាប់បណ្តឹងឧទ្ធរណ៍នៅអគ្គព្រះរាជអាជ្ញាកម្ពុជា[159]។ លើសពីនេះទៅទៀត តាមសហព្រះរាជអាជ្ញាដឹង ពេលនេះអង្គការសហប្រជាជាតិកំពុង តែពិចារណាលើសំណើសុំរបាយការណ៍ OIOS របស់សហមេធាវីការពារក្តីរបស់ នួន ជា[160]។

---

[157] សំណើ, កថាខណ្ឌ១២។

[158] *ដូចជើងទំព័រខាងលើ។*

[159] *ដូចជើងទំព័រខាងលើ។*

[160] *ដូចជើងទំព័រខាងលើ។*

00334733



៧៦. លើសពីនេះទៀត បើទោះបីជាបច្ចុប្បន្ននេះ ឧបាស្រ័យពីផ្នែកខាងក្រៅមិនត្រូវបានសម្រេចលទ្ធផលដែលត្រូវការ[161] និងសូម្បីតែមានការអះអាងថារាល់ឧបាស្រ័យពីផ្នែកខាងក្រៅទាំងអស់មិនត្រូវបានធ្វើឲ្យអស់លទ្ធភាពដើម្បីគោលបំណងនេះក៏ដោយ[162] ដើមបណ្ដឹងឧទ្ធរណ៍ នៅតែមិនបានចង្អុលបង្ហាញដល់អាជ្ញាធរណាម្នាក់ដែលអាចគាំទ្រដល់អំណាចបន្ថែមរបស់តុលាការនេះ ពាក់ព័ន្ធនឹងបញ្ហាដែលមិនស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការនេះទេ។ បញ្ហាសំខាន់ - តាមច្បាប់ ក្នុងការយល់ព្រមតាមសំណើសុំនោះ នៅតែមានការខ្វះនូវអំណាចដែលត្រូវបានប្រគល់ដល់សហចៅក្រមស៊ើបអង្កេតដដែល។

### ៥.៥ សមត្ថកិច្ចពាក់ព័ន្ធគួរតែជម្រុញឲ្យមានការផ្សព្វផ្សាយរបាយការណ៍ OIOS

៧៧. ទោះបីជាមិនមានយុត្តាធិការក៏ដោយក៏តាមពិតទៅនៅមាន "មូលហេតុផ្សេងៗដែលតម្រូវ" [163] ឲ្យ មានការលើកឡើងដោយតម្លាភាពអំពីបញ្ហានេះ ដែលអាចនឹងមានការប៉ះពាល់ដល់កេរ្តិ៍ឈ្មោះ របស់អង្គជំនុំជម្រះនេះ ដោយមិនអាចប្រកែកបាន ។ ដូចដែលបានលើកឡើងនៅក្នុងសំណើ រដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ បានដឹងអំពីបញ្ហាពុករលួយនេះរួចហើយ ។ ប៉ុន្តែនាពេលបច្ចុប្បន្ន មិនបានធ្វើអោយរបាយការណ៍OIOS រឺខ្លឹមសាររបស់ របាយការណ៍នោះលេចចេញជាសាធារណៈទេ។

៧៨. មកដល់ចុងបញ្ចប់នេះ សហព្រះរាជអាជ្ញា បានសង្កេតនិងសង្ឃឹមថាធម្មានុរូបភាពនៃនីតិវិធី របស់អង្គជំនុំជម្រះនេះ នឹងត្រូវបានជួយលើកតម្កើងឡើងតាមរយៈការបញ្ចេញរបាយការណ៍ របស់ OIOS និងតាមរយៈការដោះស្រាយមួយអំពីបញ្ហានេះ ដែលប្រកបទៅដោយការជឿ ទុកចិត្ត និងយ៉ាងទាន់ពេលវេលា ។[164]

---

[161] *ដូចដើងទំព័រខាងលើ*។

[162] *ដូចដើងទំព័រខាងលើ*, កថាខណ្ឌ១៧-១៩។

[163] *ដូចដើងទំព័រខាងលើ*, កថាខណ្ឌ១៧-១៩។

[164] សំណើ, កថាខណ្ឌ១២។

## ៦. សេចក្ដីសន្និដ្ឋាន

៧៩. សហព្រះរាជអាជ្ញាសូមស្នើឲ្យ អង្គបុរេជំនុំជម្រះ បដិសេធចោលបណ្ដឹងឧទ្ធរណ៍នេះ ។

ធ្វើនៅភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា
នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៩

**សហព្រះរាជអាជ្ញា**

**លោក យ៉េត ចាន់ធា** **លោក** William SMITH
សហព្រះរាជអាជ្ញារង សហព្រះរាជអាជ្ញារង